សមាគមបុត្តលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

១៨

* ចំណងមិត្តភាពនិងការទទួលខុសត្រូវទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សំភារៈ

# ទស្សនាវដ្ដី គ្រូបង្រៀន



របាំក្បាច់បុរាណខ្មែរ ត្រូវបានទទួលស្គាល់ជាសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ។

(ទំព័រ៤៩)

ខែ មករា - កុម្ភៈ - មិនា ឆ្នាំ ២០០៤
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុត្តលិកសិក្សាខ្មែរ
១២៨៩ មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤

# វិចារណកថា

មនុស្សជាផ្នែកមួយនៃកំលាំងផលិតកម្ម នៃបែបផែនផលិតកម្មមួយ និង ជាកត្តាកំនត់សំរេចរបស់បែបផែនផលិតកម្ម ។ ដូចនេះ ទ្រព្យសម្បត្តិពិតប្រាកដរបស់ប្រទេសជាតិ គឺមនុស្ស : មានមនុស្សជឿនលឿន គឺមានពលកម្មល្អ មានពលកម្មល្អ គឺមានសំភារៈសំបូរបែប មានជីវភាពរស់នៅសំបូរសប្បាយ ។

ការផ្លាស់ប្តូរសតិអារម្មណ៍ និង អាកប្បកិរិយារបស់ប្រជាពលរដ្ឋ ដើម្បីអោយមានគំនិតជឿនលឿន គឺជាភារកិច្ចសំខាន់បំផុតដែលថ្នាក់ដឹកនាំប្រទេសត្រូវតែពិចារណាសំដៅរកវិធានការជាអាទិភាព ។

ការអប់រំមនុស្ស គឺជាការដឹកនាំមនុស្សអោយធ្វើដំនើរឆ្ពោះទៅរកការកសាងសង្គមអោយមានការជឿនលឿនទាន់សម័យ ធ្វើយ៉ាងណាអោយមនុស្សសស្រាក់សស្រាំចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ធ្វើយ៉ាងណាអោយគេមានជំនឿយ៉ាងមុតមាំលើកំលាំង និង សមត្ថភាពខ្លួន ។

ការអប់រំនោះត្រូវតែធ្វើអោយមនុស្សមាន :

- គំនិតចង់ដឹង ចង់យល់ មានការឆ្ងល់ច្រើន
- គំនិតចូលចិត្តសង្កេតពិនិត្យដែលនាំអោយមនុស្សយល់ពីទំនាក់ទំនងរវាងហេតុ និង ផល ។
- គំនិតស្រាវជ្រាវរក "ហេតុ" ផ្សេងៗដែលនាំអោយកើតបានជា "ផល" ។ កាលណាគេរក "ហេតុ" ឃើញ គេអាចផ្លាស់ប្តូរ "ផល" បាន ។
- គំនិតចូលចិត្តធ្វើការពិសោធដែលភ្ជាប់មនុស្សទៅនឹងធម្មជាតិ អាចធ្វើអោយមនុស្សមានសមត្ថភាពកែប្រែធម្មជាតិបាន ។
- គំនិតស្រលាញ់ភាពរុងរឿងដែលជំរុញអោយមនុស្សស្រលាញ់ពលកម្ម ដើម្បីឈានទៅរកអភិវឌ្ឍន៍សង្គមដែលគេរស់នៅ ។
- គំនិតវិធីសាស្ត្រ គំនិតវិភាគ គំនិតសំយោគ តក្កវិទ្យា វិចារណញ្ញាណ មនោគតិ ។
- គំនិតតក្កកម្ម គំនិតអនុវត្តន៍ ។

ដូចនេះការអប់រំមនុស្ស ត្រូវអនុវត្តក្នុងសកម្មភាពជាក់ស្តែង និង ក្នុងការជ្រើសរើសសកម្មភាព និង វិធីសាស្ត្រសមស្របតាមលក្ខខណ្ឌអំណោយផល ។

**គណៈកម្មាធិការនាយក**

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| ២ | សេចក្តីដកស្រង់ "គោលនយោបាយយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ" | ២ |
| | **ទស្សនៈវិជ្ជាជីវៈ** | |
| ៣ | អំពីយស | ៥ |
| ៤ | អំពីបញ្ញាទឹក | ៧ |
| ៥ | ភាពជាអ្នកមានចិត្តរឹងប៉ឹង | ៩ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | របៀបអប់រំកូនក្នុងគ្រួសារ | ១១ |
| ៧ | ភាពរាយមាយរបស់សិស្ស | ១៤ |
| ៨ | ការកសាងកម្មវិធីបណ្តុះបណ្តាលបុគ្គលិក | ១៨ |
| | **វិទ្យាសាស្ត្រ និង ពត៌មានបច្ចេកវិទ្យា** | |
| ៩ | សតវត្សវិទ្យាសាស្ត្រ និង បច្ចេកទេស (១៨៦០-១៩៦០) | ២១ |
| ១០ | ម៉ាស៊ីនងាយៗ | ២២ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ១១ | ភាសា : ការប្រើប្រាស់រាជស័ព្ទក្នុងសង្គមខ្មែរ | ២៤ |
| ១២ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ២៧ |
| ១៣ | គណិតវិទ្យា : ការរាប់លេខ និង សរសេរលេខ និង ពាក្យ | ២៩ |
| ១៤ | គណិតវិទ្យា : វិធីគុណ និងវិធីចែក | ៣០ |
| ១៥ | គណិតវិទ្យា : ចំនោទ | ៣១ |
| ១៦ | សិក្សាសង្គម : សុជីវធម៌ | ៣២ |
| | **នាទីកំណាព្យ និង កំសាន្ត** | |
| ១៧ | កំណាព្យសុភាសិត | ៣៥ |
| ១៨ | ស្មារតីគ្រូបង្រៀន | ៣៦ |
| ១៩ | អក្សរចំណោទ | ៣៧ |
| ២០ | ភ្នំព្រះធាតុ | ៣៨ |
| | **វេទិកាស្វែងរៀន** | |
| ២១ | សន្តានទៃកិរិយាសព្ទ | ៤០ |
| ២២ | អំណានខុសពីសំនៀរ | ៤២ |
| | **ពត៌មាន** | |
| ២៣ | តើលោកគ្រូ អ្នកគ្រូដឹងដែរឬទេ ? | ៤៤ |
| ២៤ | សិល្បៈរបាំខ្មែរ | ៤៥ |
| ២៥ | វេទិកាស្ត្រី | ៤៦ |
| ២៦ | ភាពសុខដុមក្នុងគ្រួសារ | ៤៨ |



**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ដុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណារ៉ុណ
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី នន់ សុគ្គី
- លោក ប៉ែន សារុន
- សមាជិក-សមាជិកា ស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ សីរី
- លោកបណ្ឌិត អ៊ឹម កុច
- លោក ស៊ិន ស៊ីម
- លោក ស្មួង សារុន
- លោក ស៊ុង វ៉ាន់ថន

**វិចិត្រករ**

លោក ប៉ាន់ ត្រា

**ការិកុំព្យូទ័រ**

ក. ម៉ៃ សុធី

**គ្របខាងក្រៅ**

- ពីមុខ : របាំក្បាច់បុរាណ
- ពីក្រោយ : អគារសាធារណៈសាងសង់ក្នុងសម័យអាណានិគម

# សេចក្ដីជំរាបស្រង់

## គោលនយោបាយយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ ការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈ

### I. សេចក្ដីផ្ដើម

........................................................................................................................

........................................................................................................................

**២. ភាពផ្ទុយគ្នានៃរចនាសម្ព័ន្ធហត្ថពលករ** *(Manpower)*




**តំរូវការដំណើរការនៃប្រព័ន្ធអប់រំដែលជាប្រព័ន្ធមួយមានតុល្យ ភាពរវាងសេចក្ដីត្រូវការ និង ការផ្គត់ផ្គង់ហត្ថពលករ**

**៣. តំរូវការថ្មីចំពោះអប់រំ**

សកលភាវូបនីយកម្ម តំរូវអោយការអភិវឌ្ឍន៍ប្រព័ន្ធអប់រំមួយ ដែលបណ្ដុះបណ្ដាលអ្នកបច្ចេកទេស ដែលនឹងទទួលជោគជ័យក្នុងការប្រកួតប្រជែងក្នុងទីផ្សារពិភពលោក ។ តំរូវការថ្មីចំពោះប្រព័ន្ធអប់រំត្រូវតែ :

- អភិវឌ្ឍប្រព័ន្ធបណ្ដុះបណ្ដាលហត្ថពលករមួយ ដែលសមស្របជាមួយនឹងសេចក្ដីត្រូវការនៃអង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization) ។

- លើកកំពស់ប្រសិទ្ធភាពក្នុងប្រតិបត្តិការប្រព័ន្ធបច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការហត្ថពលករពីសង្គមឧស្សាហកម្មជឿនលឿន ។

............................................................................................................................................

............................................................................................................................................

## V. ទិសនយោបាយថ្មី *(New Policy Directions)*

............................................................................................................................................

............................................................................................................................................

### ២. ទិសដៅធំៗសំរាប់ការកែទំរង់នយោបាយ TVET នៅកម្ពុជា

ផ្អែកលើការសិក្សាវិភាគលើបញ្ហា និង ទំនាស់ដែលប្រព័ន្ធ TVET[១] យើងបាននិងកំពុងជួបប្រទះ ហើយឈរលើមូលដ្ឋាននៃការស្រាវជ្រាវអំពីនិន្នាការសកល គួបផ្សំជាមួយសភាពការណ៍ជាក់ស្តែងនៅកម្ពុជាយើង ទិសដៅចំបងនៃការកែទំរង់នយោបាយ TVET មានដូចបង្ហាញក្នុងតារាងខាងក្រោមនេះ ÷

**ការផ្លាស់ប្តូរនយោបាយជាគន្លឹះក្នុងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ**

| ល.រ | អតីត | | អនាគត |
|---|---|---|---|
| ១ | ប្រព័ន្ធដឹកនាំដោយការផ្គត់ផ្គង់ (a supply-driven system) ដែលផ្អែកលើសំណូមពរធំធេងរបស់សង្គម | ⇨ | ប្រព័ន្ធដឹកនាំដោយសំណូមពរ (a demand-driven system) ដែលណែនាំដោយសញ្ញាទីផ្សារពលកម្ម (labor market signals) |
| ២ | ប្រព័ន្ធផ្អែកលើសាលា (a school-based system) ដែលផ្តល់នូវ "សញ្ញាប័ត្រ" ដោយឈរ លើមូលដ្ឋាននៃការប្រលង | ⇨ | ប្រព័ន្ធអប់រំ និង បណ្តុះបណ្តាលដែលផ្តល់នូវ "សមត្ថភាព" (competencies) សមស្របជាមួយនឹងស្តង់ដាជាតិដែលបានទទួលស្គាល់ |
| ៣ | ប្រព័ន្ធផ្អែកលើសាលា (a school-based system) ជាមួយភាពទន់ភ្លន់អប្បបរមាក្នុងការផ្តល់ការបណ្តុះបណ្តាល(minimum flexibility in delivery) | ⇨ | ប្រព័ន្ធអប់រំបណ្តុះបណ្តាលជាមួយចំណុចចេញចូលច្រើន (multiple entry / exit points) និង ទន់ភ្លន់ក្នុងការផ្តល់ការបណ្តុះបណ្តាល (flexible delivery) |
| ៤ | គ្មានទទួលស្គាល់ជាផ្លូវការនូវការរៀនសូត្រ/បណ្តុះបណ្តាលពីមុន | ⇨ | ប្រព័ន្ធដែលទទួលស្គាល់ដោយជាក់លាក់នូវជំនាញ (skills) និង "សមត្ថភាព" "competencies" ដែលបានទទួល ទោះបីនៅទីណា និង របៀបណាក៏ដោយ |
| ៥ | ប្រព័ន្ធផ្អែកលើសាលាជាមួយការតំរង់ទិសនៃ "កម្មវិធីសិក្សា" ( "study - program" orientation) | ⇨ | ប្រព័ន្ធអប់រំបណ្តុះបណ្តាលដែលតំរង់ឆ្ពោះទៅរកមុខរបរ និងវិជ្ជាជីវៈដែលបានទទួលស្គាល់ជាផ្លូវការ |

(១) TVET: Technical Vocational Education and Training.

| | | | |
|---|---|---|---|
| ៦ | ការអប់រំ និង បណ្តុះបណ្តាលសង្កត់ធ្ងន់លើផ្នែក Formal (Formal sector) | ⇨ | ការអប់រំ និង ការបណ្តុះបណ្តាលសំរាប់ផ្នែក Formal Non-formal និង ផ្នែក Informal(*) |
| ៧ | ការបំបែកចេញពីគ្នារវាងការអប់រំ(Education) និង ការបណ្តុះបណ្តាល (Training) | ⇨ | សមាហរណកម្មពេញលេញនៃការអប់រំ និង ការបណ្តុះបណ្តាល |
| ៨ | ប្រពន្ធ័មជ្ឈការ (centralized system) នៃការគ្រប់គ្រង | ⇨ | ប្រពន្ធ័វិមជ្ឈការ (decentralized system) នៃការគ្រប់គ្រង |
| ៩ | គ្រឹះស្ថាន/ស្ថាប័នត្រូវបានផ្គត់ផ្គង់ទាំងស្រុង និង ដំណើរការដោយរដ្ឋាភិបាលកណ្តាល | ⇨ | គ្រឹះស្ថាន/ស្ថាប័នដែលផ្គត់ផ្គង់ដោយខ្លួនឯង (self supporting) និង គ្រប់គ្រងដោយខ្លួនឯង (self managing) ជាមួយនឹងការឧបត្ថម្ភភាគខ្លះពីរដ្ឋាភិបាលកណ្តាល |
| ១០ | វគ្គបណ្តុះបណ្តាលដែលផ្តល់ដោយគ្រឹះស្ថានសិក្សានៅមានកំរិតទាប ព្រមទាំងបញ្ចប់ត្រឹមតែកំរិតនេះ | ⇨ | គ្រឹះស្ថានត្រូវផ្តល់ការបណ្តុះបណ្តាលទៅកំរិតខ្ពស់ដែលជាផ្នែកមួយនៃខ្សែបច្ចេកទេស |
| ១១ | ការអប់រំ និង បណ្តុះបណ្តាលពុំបង្កលក្ខណៈទូលំទូលាយដល់អ្នកសិក្សាទាំងឡាយអោយចូលរៀន (inaccessible) | ⇨ | ប្រពន្ធ័អប់រំ និង បណ្តុះបណ្តាលត្រូវបង្កលក្ខណៈដល់អ្នកសិក្សាគ្រប់ប្រភេទអោយមានលទ្ធភាពចូលរៀន (More accessible) |
| ១២ | តំលៃសំរាប់ការអប់រំ និង បណ្តុះបណ្តាលមានកំរិតខ្ពស់ (Cost-prohibitive) | ⇨ | ធ្វើអោយការអប់រំ និង បណ្តុះបណ្តាលកាន់តែងាយស្រួលទទួលបាន (More affordable) |
| ១៣ | ការចូលរួមរបស់ស្ត្រីភេទ និង ក្រុមដែលងាយទទួលរងគ្រោះនៅមានកំរិតតិចតួចនៅឡើយ | ⇨ | បង្កើនការយកចិត្តទុកដាក់ថែមទៀតទៅលើអ្នកចូលរួម ដើម្បីអោយមានសមធម៌ |
| ១៤ | ការអប់រំ និង បណ្តុះបណ្តាលពុំទាន់ប្រកបដោយប្រសិទ្ធភាព (inefficient) | ⇨ | ប្រពន្ធ័អប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈត្រូវតែប្រកបដោយប្រសិទ្ធភាព (Efficient) |
| ១៥ | ប្រពន្ធ័អប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ពុំមានទាក់ទងទៅនឹងស្តង់ដានៅក្នុងតំបន់ | ⇨ | ប្រពន្ធ័អប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈត្រូវតែអាចប្រៀបធៀបបាននឹងប្រពន្ធ័នៅក្នុងតំបន់ |

.......................................................................................................

******

*Formal : ក្នុងប្រព័ន្ធ, Non-formal : ក្រៅប្រព័ន្ធ, Informal : ក្រៅផ្លូវការ




# អំពីយស

មនុស្សលោកបាននិងកំពុងប្រឈមនឹងលក្ខខណ្ឌជាបដិបក្ខនឹងគ្នាមួយចំនួន នៅក្នុងដំណើរប្រព្រឹត្តទៅនៃជីវិតប្រចាំថ្ងៃរបស់ខ្លួនដូចជា លាភ និង អលាភ, យស និង អយស, សរសើរ និង និន្ទា, សុខ និង ទុក្ខ ។ តទៅនេះ យើងសូមលើកយកតែ "យស" (កេរ្តិ៍កិត្តិយស)ដូចតទៅ ÷

តាមធម្មតា គេត្រូវប្រើពេលច្រើនឆ្នាំដើម្បីកសាងអាគារដ៏ប្រណីតមួយ ។ ក្នុងរយៈពេលតែមួយនាទី ពីរនាទី ដោយប្រើអាវុធទំនើបបំផ្លាញអគារដ៏ប្រណីតនោះ អាចនឹងត្រូវកំទេចបានយ៉ាងងាយ ។ យ៉ាងណាមិញ គេចំនាយពេលរាប់ឆ្នាំ រឺមួយជីវិតដើម្បីកសាងកេរ្តិ៍ឈ្មោះពិរោះពិសាមួយបាន ។ ប៉ុន្តែក្នុងមួយពព្រិចភ្នែក កិត្តិនាមដ៏ល្អកម្ររកបាននេះ អាចត្រូវរលំរលាយអស់ដោយគុណវិបត្តិមួយ : "គុណប៉ុនសំពៅ ទោសមួយចូលទៅ រលាយគុណបាត់អស់" ។ គ្មាននរណាម្នាក់ជៀសវាងផុតពីសំដីកត់សំគាល់ដ៏បង្អិនបង្អោចដែលផ្ដើមឡើងដោយពាក្យអសុរោះ "ប៉ុន្តែ" នោះទេ ។ ឧទាហរណ៍ : គាត់ជាមនុស្សល្អណាស់ គាត់បានធ្វើនេះ គាត់បានធ្វើនោះ-ល- ប៉ុន្តែប្រវត្តិរូបល្អរបស់គាត់នឹងត្រូវបានស្រអាប់ពណ៌ដោយពាក្យដែលគេហៅថា "ប៉ុន្តែ" ។ ប៉ុន្តែពាក្យអប្រិយទាំងនោះនឹងបញ្ចប់នៅកន្លែងដែលវាចាប់ផ្ដើម ។ វីរជន រឺមហាបុរសទាំងឡាយ មិនញញើតនឹងប្រឈមមុខនឹងពាក្យវាយប្រហារ និង ពាក្យជេរប្រទេចឡើយ ។ ឆ្កែចេះតែព្រួស មនុស្សចេះតែដើរ ។ យើងកំពុងតែនៅក្នុងពិភពលោកមានភក់ល្បាប់ ។ ផ្កាឈូកជាច្រើនដុះចេញពីទីនេះ ដោយមិនបានជាប់ក្លិនភក់ល្បាប់ទេ ។

ជាក់ស្ដែង ព្រះពុទ្ធគឺជាតួអង្គដ៏មានកិត្តិនាមល្បីល្បាញបំផុត ក៏ប៉ុន្តែក៏ជាសាស្ត្រាចារ្យត្រូវគេបង្កាច់បង្ខូចព្រះកិត្តិនាមព្រះអង្គដ៏ខ្លាំងបំផុតនៅក្នុងសម័យកាលព្រះអង្គគង់ព្រះជន្មនៅឡើយ ។ មហាបុរសទាំងឡាយ ជាញឹកញយត្រូវបានគេស្គាល់ តែទោះជាយ៉ាងណាក្ដីក៏ត្រូវមានគេបង្អាប់បង្អោនផងដែរ ។

ពួកអ្នកប្រឆាំងព្រះពុទ្ធអង្គខ្លះបានផ្សាយពាក្យចចាមអារាមថា ព្រះអង្គធ្លាប់រួមរក្សជាមួយស្ត្រីម្នាក់ក្នុងវត្ត ។ ក្រោយពេលការប៉ុនប៉ងដ៏ថោកទាបទទួលបរាជ័យ ពួកគេបានផ្សាយដំណឹងខុសក្នុងចំនោមប្រជាជនថា ព្រះពុទ្ធហើយនិងសាវកទាំងឡាយរបស់ព្រះអង្គបានសំលាប់ស្ត្រីដដែលនោះ ហើយបានលាក់សាកសពស្ត្រីនោះនៅក្នុងគំនរសំរាមនៃផ្កាស្រពោនក្រៀមនៅក្នុងបរិវេណវត្ត ។ ពួកជនទុច្ចរិតនៅពេលក្រោយមកក៏បានអះអាងថា ក្នុងរឿងនេះពួកគេគឺជាពិរុទ្ធជន ។

កាលដែលបេសកកម្មជាប្រវត្តិសាស្ត្ររបស់ព្រះពុទ្ធអង្គបានទទួលជោគជ័យត្រចះត្រចង់ ដោយមានមនុស្សជាច្រើន

បានចូលមកសុំផ្ទួសជាមួយព្រះអង្គ ពួកមារសត្រូវចំពោះព្រះអង្គបានមួលបង្កាច់ព្រះអង្គដោយនិយាយថា ព្រះអង្គបានពង្រាត់បង្រាស់កូនប្រុសពីម្តាយ ពង្រាត់បង្រាស់ប្តីពីប្រពន្ធ ហើយចោទប្រកាន់ព្រះអង្គថាវាំងស្ទះវឌ្ឍនភាពរបស់ជាតិ ។ តែការប៉ុនប៉ងទាំងអស់នេះ ដើម្បីបំផ្លាញចរិតដ៏ប្រសើររបស់ព្រះអង្គត្រូវជួបបរាជ័យ ។ ជីដូនមួយផ្ទាល់របស់ព្រះអង្គឈ្មោះ ទេវទត្ត ដែលជាសាវកច្រណែនឈ្នានីសមួយរូបរបស់ព្រះអង្គ បានប៉ុនប៉ងធ្វើឃាតព្រះអង្គ ដោយប្រានថ្មទំលាក់ពីលើកំពូលភ្នំមក ក៏ប៉ុន្តែទេវទត្តត្រូវបរាជ័យក្នុងការប៉ុនប៉ងនោះ ។

ប្រសិនបើព្រះអង្គជាតួអង្គសុក្រឹត មានបារមីបរិបូណ៌ឥតកំហុសទទួលរងវាសនាអាប់អួដូចនេះទៅហើយ ទំរាំមនុស្សធម្មតាមិនទាន់មានភាពសុក្រឹត គេចវេះដូចម្តេចផុតពីវាសនាអាក្រក់បាន ។

លោកអ្នកឡើងលើភ្នំកាន់តែខ្ពស់ លោកអ្នកកាន់តែលេចធ្លោ ហើយស្ថិតក្នុងក្រសែភ្នែកនៃមនុស្សដទៃ ។ ខ្នងរបស់លោកអ្នកត្រូវបានគេមើលឃើញច្បាស់ ប៉ុន្តែផ្ទៃកខាងមុខបិតនៅកំបាំង ។ ពួកអ្នកស្វែងរកកំហុសលាតត្រដាងកំហុសឆ្គង និង ចំនុចសង្ស័យ រឺខ្វះទំនុកចិត្តរបស់លោកអ្នក ប៉ុន្តែពួកគេបំភ្លេចគុណធម៌ដ៏លេចធ្លោរបស់លោកអ្នក ។ ត្បាល់បក់បង្ហើរយកចេញនូវធូលីសំរាម រឺដៅ[១] ប៉ុន្តែរក្សាទុកគ្រាប់ធញ្ញជាតិ ផ្ទុយទៅវិញតំរងច្រោះរក្សាទុកកាកសំនល់ ប៉ុន្តែបង្ហូរទឹកដមផ្អែម ។ ជនមានវប្បធម៌បណ្តុះបណ្តាលហើយ រមែងក្រេបយករសជាតិឈ្ងុយឆ្ងាញ់ ហើយខ្ទាក់ចោលកាកសំនល់ ជនគ្មានវប្បធម៌រក្សាទុកកាកសំនល់ ប៉ុន្តែបោះបង់ចោលរសជាតិដ៏ឈ្ងុយឆ្ងាញ់នៃវិជ្ជា ។

ប្រការនេះ យើងមិនគួរគប្បីចំនាយពេលកែតំរូវសេចក្តីរាយការណ៍ខុសឆ្គង ប្រសិនបើកាលៈទេសៈមិនតំរូវអោយលោកអ្នកចាំបាច់ត្រូវបំភ្លឺទេ ។ សត្រូវសប្បាយចិត្តណាស់ កាលណាគេឃើញថា លោកអ្នកមានការឈឺចាប់ នោះហើយគឺជាចំនុចដែលគេរង់ចាំដោយពិតប្រាកដ ។ ប្រសិនបើលោកអ្នកសោះអង្គើយវិញ ការនិយាយបង្ខូចកេរ្តិ៍ឈ្មោះបែបនោះនឹងគ្មាននរណាយកត្រចៀកស្តាប់ទេ ។

ពិភពលោកនេះពោរពេញដោយបន្លា និង គ្រួសថ្ម ។ គេមិនអាចយកបន្លា គ្រួសថ្មបានអស់ទេ ។ វាជារឿងចំលែកណាស់ដែលមហាបុរសទាំងឡាយត្រូវបានគេនិយាយមួលបង្កាច់ គេសំអុយកេរ្តិ៍ គេបំពុល គេឆ្កាង រឺគេបាញ់សំលាប់ ។ លោកសូក្រាតត្រូវគេបំពុល ។ ព្រះយេស៊ូ ត្រូវគេចងឆ្កាងយ៉ាងឃោរឃៅ ។ លោកមហាត្មៈគន្ធី ត្រូវគេបាញ់សំលាប់ ។ ដូចនេះគេសង្កេតឃើញថា ការប្រព្រឹត្តល្អពេក វាជាគ្រោះថ្នាក់ ។ ក្នុងអំឡុងពេលរស់នៅ លោកទាំងនោះត្រូវគេរិះគន់ ត្រូវគេវាយប្រហារ និង ត្រូវគេសំលាប់ ។ ក្រោយពេលមរណភាព លោកទាំងនោះត្រូវបានគេលើកតំកើងជាទេវតា និង ផ្តល់កិត្តិយស ។

មហាបុរសទាំងឡាយ មិនខ្វល់នឹងកេរ្តិ៍ឈ្មោះ រឺអាប់កិត្តិយសនោះទេ ។ លោកទាំងនោះមិនខូចចិត្ត កាលណាត្រូវគេរិះគន់ រឺមួលបង្កាច់ ពីព្រោះលោកធ្វើការមិនមែនដើម្បីយកមុខមាត់ រឺកេរ្តិ៍ឈ្មោះនោះទេ ។ លោកមិនរវល់ថាតើអ្នកឯទៀតទទួលស្គាល់ស្នាដៃរបស់លោក រឺអត់នោះ លោកមិនដែលបានគិតអំពីផ្លែផ្កាដែលលោកបានធ្វើនោះទេ ។

ដកស្រង់ដោយ : **កែវ សុបុរិន្ទ**

រឿងពិតនៃជីវិត : ការផ្សាយរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ

ព.ស. ២៥៤៥ គ.ស. ២០០២

(១) ចំបើងដែលបែននៅជជុះយកគ្រាប់ស្រូវម្តងទៀតទើបសំរេចទៅជាចំបើងមែនទែន

# អំពីបញ្ហាទឹក

បញ្ហាទឹកកំពុងចោទនៅលើផែនដីយើងនេះ ។ សព្វថ្ងៃ បញ្ហាកង្វះទឹកកាន់តែដុះដាលឡើង ព្រោះប្រជាជនកើន ការប្រើប្រាស់ក៏កើនទៅតាមចំនួនមនុស្សដែរ ហើយបរិមាណទឹកស្អាតសំរាប់ប្រើប្រាស់នៅស្ថេរជានិច្ច : ក្នុងសតវត្សនេះ កង្វះទឹកត្រូវបានចាត់ទុកជារបាំងយ៉ាងធំធេងដល់ការអភិវឌ្ឍ ។

ក្នុងន័យនេះហើយ យូណេស្កូ (UNESCO) ដាក់បញ្ហាទឹកទៅក្នុងកិច្ចនៃសហប្រតិបត្តិការ ។ ទន្លេមេគង្គក៏ត្រូវបានធ្វើយ៉ាងដូចនេះដែរ : យើងមានគណៈកម្មាធិការទន្លេមេគង្គ... ។

## កង្វះទឹកនៅឆ្នាំ ២០២៥




កន្លងមក សន្និសីទនៅទីក្រុងរីយ៉ូ (Rio) នាឆ្នាំ ១៩៩២ បានគូសបញ្ជាក់អំពីសារៈសំខាន់របស់ទឹកក្នុងទំនាក់ទំនងអន្តរជាតិ ។ បច្ចុប្បន្ននេះ ការស្រាវជ្រាវជាច្រើនបានអះអាងថា ក្នុងអំឡុងរយៈពេលដប់ឆ្នាំខាងមុខនេះ ប្រទេសកំពុងអភិវឌ្ឍនឹងក្លាយជាអ្នករងមុនគេអំពីកង្វះទឹក ។

ល្មើកណាតំរូវការកើន ល្មើកនោះបញ្ហាទឹកនឹងបង្កអោយមានទំនាស់ក្នុងការប្រើប្រាស់ ។ មានមនុស្សរាប់លាននាក់ទៅហើយនៅលើផែនដីនេះដែលរងគ្រោះដោយសារកង្វះទឹក ។ ប្រសិនបើយើងមិនមានការផ្លាស់ប្តូរបែបបទ និង ការគ្រប់គ្រងប្រភពនោះទេ នោះគ្រោះមហន្តរាយដ៏សំបើមនឹងមានចំពោះផែនដីក៏ដូចជាមនុស្សរស់នៅលើផែនដី ។

កម្មវិធីពិភពលោកដើម្បីធ្វើការវាយតំលៃប្រភពធនធានខាងទឹក (WWAP) ត្រូវបានបង្កើតនៅឆ្នាំ ២000 ក្នុង គោលបំណងរកដំណោះស្រាយស្ថិតស្ថេរចំពោះបញ្ហាអភិវឌ្ឍន៍របស់មនុស្ស ។ មានភ្នាក់ងារចំនួន ២៣ របស់អង្គការ សហប្រជាជាតិបានចូលរួមក្នុងកម្មវិធីនេះដែលត្រូវនៅក្រោមដំបូលយូណេស្កូ (UNESCO) ។

គំនិតផ្ដួចផ្ដើមនេះ កើតឡើងដោយសារមតិសាធារណៈពិភពលោកស្ដីពីបញ្ហាទឹកដែលបានប្រព្រឹត្តទៅនៅទីក្រុងឡាអេ (La Haye) នាឆ្នាំ ២០០០ ហើយត្រូវបានទទួលការគាំទ្រពីសំណាក់សេចក្ដីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រីដែលផ្ដួចផ្ដើមរកច្រកចេញចំពោះបញ្ហានេះ ។

អង្គការ WWAP បានបង្ហាញយ៉ាងច្បាស់នូវរបាយការណ៍ពិភពលោកជាមួយនឹងរបាយការណ៍ផ្សេងៗទៀតស្ដីពីការអភិវឌ្ឍនៃប្រភពធនធានទឹក ។ ឯកសារនោះមិនមែនគ្រាន់តែធ្វើការវាយតំលៃលើសភាពនៃធនធានទេ តែក៏បានបង្ហាញអំពីការអភិវឌ្ឍសំរេចបានដើម្បីឆ្លើយតបនឹងតំរូវការ ។ ការបោះពុម្ពលើកទី១ត្រូវបានផ្សព្វផ្សាយនាឆ្នាំ ២០០៣ ។

ក្រៅពីនេះ អង្គការ WWAP នៅមានឯកសារមួយទៀតដែលមានចំនងជើងថា "ពីទំនាស់ទៅកាន់សហប្រតិបត្តិការ" ។ គំរោងនេះ សំដៅដោះស្រាយរឿងរ៉ាវលើកឡើងពីបញ្ហាទឹកដែលបានកើនឡើង និង អាចបង្កជាទំនាស់អន្តរជាតិរវាងប្រទេស ១៤៥ ដែលមានទន្លេ និង អាងរួមគ្នា ២៦១ ។ ប្រការនេះ ទឹកអាចក្លាយជាប្រភពនៃការប្រឈមមុខដាក់គ្នា ។ ប៉ុន្តែការគ្រប់គ្រងធនធាននេះបានល្អ អាចនាំទៅដល់ការបង្កើត រឺការពង្រឹងទំនាក់ទំនងសហប្រតិបត្តិការមានផលប្រយោជន៍ទៅវិញទៅមក ។

ការសិក្សា ការផ្សព្វផ្សាយ និង សកម្មភាពអប់រំជាបន្តបន្ទាប់ត្រូវបានខិតខំរៀបចំដោះស្រាយភាពស្មុគស្មាញនៃទិដ្ឋភាពសង្គមវប្បធម៌ វិទ្យាសាស្ត្រ និង នយោបាយដែលមានបញ្ហាពាក់ព័ន្ធនៅក្នុងតំបន់ព្រំប្រទល់ដែលមានទីបំរុងទឹក ។

ប្រែសំរួលដោយ : **កែច យ៉ារ**

////📖///

**ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ**

ខេមរភាសិត

# ភាពជាអ្នកមានចិត្តរឹងប៉ឹង

គុណសម្បត្តិដ៏សំខាន់បំផុតក្នុងខ្លួនវីរបុរស រឺមហាបុរស គឺភាពជាអ្នកមានចិត្តរឹងប៉ឹង ហើយជនដែលមាំទាំរឹងប៉ឹងនេះទៀតសោត តែងជាអ្នកទន់ភ្លន់ ។ លក្ខណៈនៃជនទាំងនោះអាចរួមមាន ៤ ប្រការ ÷

១- មិនចេះពោល ថ្ងូរ

២- មិនត្រូវការចង់ដឹងថា អ្នកដទៃនឹងគិតពីខ្លួនថាយ៉ាងដូចម្ដេច ។

៣- មិនប្រាប់អាថិកំបាំងរបស់ខ្លួនដល់អ្នកដទៃ និង មិនត្រូវការចង់ដឹងការអាថិកំបាំងរបស់អ្នកដទៃ ។

៤- មិនគិតថា ខ្លួនជាមនុស្សមានគ្រោះអាក្រក់ អាចនឹងនាំយកហេតុការណ៍ផ្សេងៗមកធ្វើជាប្រយោជន៏ដល់ខ្លួនបានទាំងអស់ ។

- ជនដែលពោល ថ្ងូរនោះ សំដែងអោយឃើញភាពទន់ខ្សោយ ខ្វះការតស៊ូចំពោះសេចក្ដីលំបាក ឬក៏យ៉ាងហោចមិនចេះលាក់បាំងទុកក្នុងចិត្ត ត្រូវតែនិយាយអោយគេដឹង ។ ការដែលបង្ហាញអោយមនុស្សទូទៅដឹងថា ខ្លួនបានទទួលការលំបាកនោះ ជាផលដ៏អាក្រក់មួយធ្វើអោយជនទាំងឡាយមើលឃើញថា ខ្លួនមិនមាំទាំគ្រប់គ្រាន់សំរាប់ធន់ចំពោះការលំបាក ។ បើការលំបាកនោះ បង្កើតឡើងដោយជនដទៃក្លែងធ្វើអោយលំបាកផងនោះ ជនដែលក្លែងនោះ រឹតតែសប្បាយចិត្ត បន្ថែមការបៀតបៀនកាន់តែខ្លាំងថែមទៀត ។ ប៉ុន្តែជនដែលមិនថ្ងូរ ខំតស៊ូចំពោះការលំបាកដោយស្ងៀមស្ងាត់ រមែងធ្វើអោយជនទាំងឡាយមើលឃើញនូវភាពមាំទាំ រឹងប៉ឹងគួរអោយគោរព កោតខ្លាច និង ធ្វើអោយជនដែលប្រទូស្តរាយពុំរីករាយ ព្រោះគេពុំបានជ័យជំនះ ។ បើទុកជា គេគិតបន្តប្រទូស្តរាយក៏គេដឹងថា មិនអាចយកជ័យជំនះបាន និង រអាលែងហ៊ានធ្វើតទៅទៀតផង ។
- ជនដែលមានលក្ខណៈរឹងប៉ឹង តែងមានការទុកចិត្តចំពោះខ្លួនឯង ចំពោះអ្វីដែលបានពិចារណាត្រឹមត្រូវហើយ ទោះបីអ្នកណាពោលអាក្រក់ល្អយ៉ាងណាក៏ដោយ ។ ជនដែលឧស្សាហ៍ស៊ើបសួរចង់ដឹងថា អ្នកដទៃយល់ឃើញចំពោះខ្លួនយ៉ាងណានោះ ក៏ព្រោះមិនប្រាកដក្នុងចិត្តខ្លួនឯងថា អ្វីដែលធ្វើទៅហើយនោះ ត្រូវ ឬខុស ។ ជនប្រភេទនេះ តែងខ្សឹបខ្សៀវស៊ើបសួរជានិច្ចថា តើចៅហ្វាយនាយមាននិយាយពីខ្លួនដូចម្ដេចខ្លះ ។ ផ្ទុយទៅវិញ ជនដែលមានលក្ខណៈរឹងប៉ឹងតែងជឿជាក់ថាខ្លួនធ្វើត្រូវមិនព្យាយាមចង់ដឹងថា អ្នកណានិយាយពីខ្លួនដូចម្ដេចទេ ។
- ការលាតត្រដាងអាថិកំបាំងរបស់ខ្លួនអោយអ្នកដទៃស្ដាប់ ឬការព្យាយាមចង់ដឹងអាថិកំបាំងអ្នកដទៃ ជាលក្ខណៈនៃភាពទន់ខ្សោយ ។ ជនខ្លះលាក់អាថិកំបាំងមិនបាន នឹងធ្វើអោយប្រេះទ្រូង ត្រូវតែដើរប្រាប់អ្នកនេះអ្នកនោះ រួចហើយបន្ថែមពាក្យថា កុំនិយាយទៅទៀត ដែលខ្ញុំនិយាយអោយស្ដាប់នេះ ព្រោះខ្ញុំទុកចិត្តទើបនិយាយ ។ តែដល់ទៅជួបអ្នកណាម្នាក់ទៀត ក៏និយាយអោយស្ដាប់

ទៀត ហើយក៏បន្ថែមពាក្យហាមដដែលនោះទៀត ។ ជនខ្លះទៀត មានការខ្វល់ខ្វាយក្នុងការចង់ដឹងរឿងអាថិកំបាំងរបស់អ្នកដទៃ បើបានដឹងហើយ ទោះជារឿងគ្មានប្រយោជន៍ក៏ដោយក៏រីករាយស្រស់ស្រាយប្រហែលគ្នានឹងបានទទួលទានអាហារដ៏មានឱជារស ។ ព្រោះហេតុនោះ ទើបវិធីដែលនឹងមើលលក្ខណៈរបស់មនុស្សដ៏ល្អមួយគឺ បើនរណាមួយជាអ្នកនិយាយការអាថិកំបាំងអោយយើងស្ដាប់ដោយគ្មានហេតុផល ឬចូលចិត្តខ្សឹបខ្សៀវ ចង់ដឹងរឿងផ្ទាល់ខ្លួនអ្នកដទៃនោះ អ្នកនោះជាមនុស្សទន់ខ្សោយមិនគួរគោរពរាប់អានជឿស្ដាប់ឡើយ ។

- មានលក្ខខណ្ឌដែលគួរអោយជឿថា ជោគអាក្រក់មិនអាចយកឈ្នះលើយើងបានទេ លុះត្រាតែយើងសុខចិត្តចុះចាញ់វា ។ អ្នកដែលមានលក្ខណៈរឹងប៉ឹង រមែងមិនអើពើចំពោះជោគអាក្រក់ឡើយ ។ បើទុកជាមានហេតុការណ៍ណាមួយកើតឡើង ក៏មិនទទួលផលពីហេតុការណ៍នោះទេ បែរជាទាញយកហេតុការណ៍នោះ ជាឧបករណ៍ធ្វើសេចក្ដីល្អចំពោះខ្លួនបានគ្រប់យ៉ាង ។ អ្នកសិក្សាដែលមានលក្ខណៈទន់ខ្សោយ តែងតែទោមនស្សរហូតដល់សំលាប់ខ្លួនក៏មាន កាលបើប្រលងធ្លាក់ ។ តែអ្នកសិក្សាដែលមានលក្ខណៈមាំទាំ ឥតមានតូចចិត្តទេ ព្រោះបើប្រលងជាប់ក៏គិតឃើញថានឹងឡើងរៀនថ្នាក់ខ្ពស់ទៅទៀត បើប្រលងធ្លាក់ក៏គិតឃើញថានឹងរៀនអោយបានច្បាស់លាស់ទៀត ។

មនុស្សដែលមានលក្ខណៈរឹងប៉ឹង ក្រៅពីលក្ខណៈ ៤ ប្រការនេះ នៅមានលក្ខណៈដទៃទៀតដែលយើងអាចងាយកត់សំគាល់គឺ ជាមនុស្សមិនកញ្ជក់កញ្ជែង មានការត្រិះរិះ មិនធ្វើកាយវិការឥតប្រយោជន៍ និយាយស្ដីច្បាស់ៗ និងមានឥរិយាបថនឹងនរជានិច្ច ។

ដកស្រង់ដោយ : **កែវ យ៉ារ**

❧❧❧ ❦ ❧❧❧

- **មនុស្សល្ងង់ គេធ្វើអោយពេញចិត្តបានដោយងាយ ។**
- **មនុស្សចេះដឹងពិសេស គេធ្វើអោយពេញចិត្តរឹតតែងាយទៅទៀត ។**
- **តែឯបុគ្គលមានការចេះដឹងបន្តិចបន្តួច កុំថាឡើយត្រឹមមនុស្ស ព្រះព្រហ្មក៏ធ្វើអោយពេញចិត្តមិនបានដែរ ។**

ស្រីហិតោបទេសភាគទី ៤

(កសាងខ្លួនឯង : ទស្សនវិជ្ជាលំហាត់ចិត្តរឹងប៉ឹងសំរាប់ដឹកនាំមនុស្សជាតិ)



# ចិត្តវិទ្យា-អប់រំ

## របៀបអប់រំកូនក្នុងគ្រួសារ

លទ្ធផលនៃការអប់រំអាស្រ័យនឹងកត្តា បី យ៉ាង : កត្តាគ្រួសារ កត្តាសង្គម និង កត្តាសាលារៀន ។ នៅបណ្ដាប្រទេសជាច្រើនដូចជា សហរដ្ឋអាមេរិកជាដើម សុទ្ធតែមានគោលនយោបាយជូនរង្វាន់ដល់គ្រួសារទាំងឡាយណាដែលដើរតួជាគ្រូទីមួយដ៏ល្អរបស់កូននៅក្នុងគ្រួសារ ព្រោះការអប់រំផ្នែកសីលធម៌ល្អ ទំលាប់ល្អ គំរូល្អ ទឹកចិត្តចង់រៀន គ្រួសារមានឥទ្ធិពលខ្លាំងក្លាណាស់ ។ ខាងក្រោមនេះជាឧទាហរណ៍ជាក់ស្ដែងនៅក្នុងគ្រួសារចំនួនបី ÷

**១. គ្រួសារផ្ដាច់ការ** *(Authoritarian parent)*

**ម្ដាយ** : សូភី មកហូបបាយ !

**សូភី** : (កំពុងមើលទូរទស្សន៍) មិនឆ្លើយតបអ្វីទាំងអស់ ។

**ម្ដាយ** : (ដើរចូលទៅក្នុងបន្ទប់រួចបិទទូរទស្សន៍) ឈប់មើល ! បាយដួសរួចហើយ ។

**សូភី** : បើកទូរទស្សន៍សាជាថ្មី ។

**ម្ដាយ** : ចេញភ្លាម ! ទៅហូបបាយ! ។

នៅក្នុងគ្រួសារមួយដែលមានការគ្រប់គ្រងបែបនេះ តែងតែបណ្ដាលអោយកូនក្លាយជាមនុស្សអោយតំលៃខ្លួនឯងទាប *(Low self - esteem)* មានអារម្មណ៍ភ័យខ្លាច មិនចាប់អារម្មណ៍ក្នុងការរៀនសូត្រ *(Baumrind-1967)* ។

**២. គ្រួសារដែលមានការអនុញ្ញាត** *(Permissive parent)*

**ម្ដាយ** : ដល់ពេលហូបបាយហើយ ធារីបិទទូរទស្សន៍ទៅ! ។

**ធារី** : (មិនមានការឆ្លើយតប) ។

**ម្ដាយ** : កូនអើយ ចេញមក ដល់ពេលហូបបាយហើយ ។

**ធារី** : (នៅស្ងៀមមិនឆ្លើយតប) ។

**ម្ដាយ** : ដើរទៅជិត រួចប្រាប់ថា កូនអើយមកហូបបាយ !

**ធារី** : ខ្ញុំមិនទាន់ចង់ហូបទេ ខ្ញុំបន្តមើលរឿងនេះបន្តិចទៀតសិន ។

**ម្ដាយ** : ត្រលប់ទៅតុហូបបាយ ព្រមទាំងនិយាយថា : យី ! ម្ដេចក៏យ៉ាងហ្នឹង ។

**ធារី** : ៥ នាទីក្រោយមក ធារីបានទៅតុហូបបាយរួចហើយចាប់យកបាយ និង ម្ហូបដាក់ចាន ។

**ម្ដាយ** : អង្គុយមកកូន ព្រមទាំងហូបបាយជុំគ្នា នៅទីនេះហើយ ។

**ធារី** : តើខ្ញុំអាចយកទៅហូបកន្លែងផ្សេងបានទេ ?

**ម្ដាយ** : *(Sighing)* បាន ទៅចុះ ។

នៅក្នុងគ្រួសារធារី ម្ដាយមិនបានត្រួតត្រាគំរាមកំហែងកូនទេ ។ គាត់មិនបានយកវិន័យតឹងតែងមកបង្ខំកូនអោយបានជាដាច់ខាតនោះទេ ។ ផ្ទុយទៅវិញ កូននៅក្នុងគ្រួសារនេះត្រូវបានអនុញ្ញាតក្នុងការប្រព្រឹត្តអោយបានត្រឹមត្រូវដោយខ្លួនឯងទៅតាមការសំរេចចិត្តផ្ទាល់របស់កូនរួចប្រាប់អោយឪពុកម្ដាយបានដឹងៗ ។

ចិត្តវិទូបានសង្កេតឃើញថា ការធ្វើបែបនេះមិនត្រឹមត្រូវទេ ព្រោះកុមារមិនទាន់មានសមត្ថភាពត្រួតពិនិត្យធ្វើជាម្ចាស់របស់ខ្លួននៅឡើយទេ ។ ជាពិសេសនៅក្នុងសង្គមបច្ចុប្បន្ន វាទាមទារសមត្ថភាពធ្វើជាម្ចាស់នៃខ្លួនឯងអោយបានរឹងមាំ ហើយសមត្ថភាពធ្វើជាម្ចាស់ខ្លួនឯងរឹងមាំនេះ វាអាស្រ័យទៅនឹងភាពពេញវ័យ ការអប់រំ និងលក្ខណៈពិសេសរបស់បុគ្គលដែរ ។ ដូចនេះ ការផ្ដល់សេរីភាពជ្រុល បណ្ដាលអោយកុមារក្លាយទៅជាមនុស្សមានះ *(impulsive)* និង កំរោលឃោរឃៅ *(aggressive)* ខ្វះទាំងសមត្ថភាពសំរេចចិត្តអោយបានត្រឹមត្រូវ និង ភាពម្ចាស់ការ *(Lacking both self – reliance and self – control)* ។ លុះធំឡើង កុមារដែលនៅក្នុងគ្រួសារបែបនេះនឹងក្លាយជាមនុស្សខ្វះទាំងទំនួលខុសត្រូវសង្គម និង ភាពម្ចាស់ការ ។ ប៉ុន្តែគេក៏ជាមនុស្សដែលចូលចិត្តសេចក្ដីសប្បាយ ចូលចិត្តនិយាយលេងសើចជាងកូនមកពីគ្រួសារផ្ដាច់ការដែរ ។

### ៣- គ្រួសារដែលពន្យល់ហេតុផល *(Authoritative parents)*

**ម្ដាយ** : សុភ័ក ដល់ពេលហូបបាយហើយ បិទទូរទស្សន៍ និង មកហូបបាយ! ។

**សុភ័ក** : (មិនឆ្លើយតប) ។

**ម្ដាយ** : (ចូលទៅក្នុងបន្ទប់) សុភ័ក ម៉ាក់និយាយយ៉ាងម៉េច អំបាញ់មិញ ?

**សុភ័ក** : បិទទូរទស្សន៍ ។

**ម្ដាយ** : ត្រឹមត្រូវណាស់ ។ ឥឡូវ ចូរកូនបិទវាទៅ ។ គ្រួសារយើងចង់អោយកូនៗទាំងអស់អង្គុយហូបបាយជុំគ្នា ។ ដូចនេះ កូនអាចនិយាយប្រាប់ដល់គ្នា អំបាញ់មិញនេះ កូនបានមើលរឿងអ្វី ? ដំណើររឿងយ៉ាងម៉េចខ្លះ ? យើងត្រូវតែទៅហូបឥឡូវនេះ ព្រោះថាបើចាំបន្តិចទៀត ម្ហូបវានឹងត្រជាក់អស់ហើយ ។

**សុភ័ក** : ទៅអង្គុយហូបជុំគ្នា ។

នៅក្នុងគ្រួសារនេះ ម្ដាយបានប្រាប់វិន័យដ៏ត្រឹមត្រូវដល់កូនទាំងអស់ ព្រមទាំងខិតខំពន្យល់អំពីហេតុផលដោយសង្ឃឹមថា កូនចៅទាំងអស់នឹងសហការអនុវត្តអោយបានសំរេច ។ នៅក្នុងគ្រួសារនេះ ប្រសិនបើរឿងដែលកូនកំពុងមើលនោះមានលក្ខណៈពិសេសសំខាន់ ម្ដាយក៏អាចរង់ចាំដោយពន្យារពេលមួយរយៈនៃការចាប់ផ្ដើមហូបបាយផងដែរ ។ នៅក្នុងគ្រួសារបែបនេះ ម្ដាយឪពុកមានប្រសិទ្ធភាពខ្ពស់ក្នុងការអប់រំកូន ពីព្រោះគាត់បានខិតខំ

ពន្យល់ហេតុផល ព្រមទាំងប្រព្រឹត្តទៅលើកូនដោយសុភាពរាបសារទន់ភ្លន់ តែម៉ឺងម៉ាត់ ដើម្បីអោយកូនគោរពវិន័យមាតាបិតាព្យាយាមពន្យល់ហេតុផលដើម្បីអោយកូនយល់បានថា ហេតុអ្វីបានជាកូនត្រូវធ្វើបែបនេះនឹងចៀសវាងអំពើបែបនោះ ។

ដូច្នេះ នៅក្នុងគ្រួសារនេះ ម្តាយឪពុកដាក់វិន័យផង និង អប់រំពន្យល់អំពីហេតុផលផង ។ កុមារនៅក្នុងគ្រួសារនេះនឹងមានការពឹងពាក់ខ្ពស់លើសមត្ថភាពខ្លួន ព្រមទាំងមានអារម្មណ៍រីករាយក្នុងជីវិតខ្លួនទៀតផង ។ *(High level of self reliance, self – control Cheerfulness (Baumrind – 1967)* គេនឹងក្លាយទៅជាមនុស្សដែលអោយតំលៃខ្ពស់មកលើខ្លួនគេ *(self – esteem Coopersmith 1967)* ។

សរុបមក របៀបរបបគ្រប់គ្រងគ្រួសារមានប្រសិទ្ធភាពក៏អាស្រ័យទៅនឹងកត្តាសង្គម សហគមន៍ និង វប្បធម៌ផងដែរ ។ បើតាមប្រសាសន៍របស់លោក *Lytton (1988)* ចំពោះគ្រួសារផ្តាច់ការក៏មានផលល្អដែរ នៅក្នុងសហគមន៍ដែលពោរពេញទៅដោយគ្រោះថ្នាក់ រឿងអាស្រូវ ការប្លន់ ចាប់ពង្រត់ និង គ្រឿងញៀន*(Lytton 1988)*។ ក៏ប៉ុន្តែ ដើម្បីរួមចំណែកអប់រំកូនឈានទៅរកភាពម្ចាស់ការ អោយតំលៃខ្ពស់មកលើខ្លួនឯង មានសុខភាពផ្លូវចិត្តល្អ ព្រមទាំងប្រាជ្ញាវាងវៃ គួរមាតាបិតាប្រើប្រាស់របៀបគ្រប់គ្រងកូនតាមប្រភេទ "ពន្យល់ហេតុផលនៃបំណងល្អរបស់ឪពុកម្តាយ ដើម្បីអោយកូនបានយល់ដឹង និង ឯកភាពទទួលយកធ្វើតាមទាំងរីករាយ" ។

បណ្ឌិត : **អ៊ុំ កុច** ព្រឹទ្ធបុរសរង
នៃមហាវិទ្យាល័យគរុកោសល្យ

| | | |
|---|---|---|
| **ឱកូនកុំខា** | **ធម្មតាអ្នកជា** | **អោយរៀនថែទាំ** |
| **រៀនដាក់រៀនទុក** | **រៀនរៀបរៀនចំ** | **រៀនរកសន្សំ** |
| | **លក់ចេញទិញចូល ។** | |
| **មួយសោតឯច្បាប់** | **បើបានមានទ្រព្យ** | **មនុស្សផងមកមូល** |
| **ពឹងពាក់ប្រាណណា** | **បាយកប្រមូល** | **សន្សំផ្សំចូល** |
| | **យកមកជាមួយ ។** | |
| | | ច្បាប់បណ្តាំបិតា |

# ភាពរាយមាយរបស់សិស្ស

## មូលហេតុនៃភាពរាយមាយរបស់សិស្សក្នុងការសិក្សា

មូលហេតុទាំងអស់កើតមកពីមជ្ឈដ្ឋានផ្សេងៗគ្នាជាច្រើន ហើយតាមទស្សនៈរបស់ពួកចិត្តវិទូខ្លះបានបែងចែកមូលហេតុទាំងនេះមាន ៤ យ៉ាង : មូលហេតុនៃជំងឺផ្លូវចិត្ត មូលហេតុនៃកំរិតបញ្ញា មូលហេតុនៃសេចក្តីស្រលាញ់ និង មូលហេតុនៃសរីរាង្គកាយ ។

**ក. មូលហេតុជំងឺផ្លូវចិត្ត** : ត្រូវបានគេប្រទះឃើញនៅក្នុងករណីផ្សេងៗគ្នា ក៏ប៉ុន្តែមូលហេតុទាំងនេះអាចកើតឡើងដោយសារតែភាពមិនឋិតថេររបស់សរីរាង្គចលករក្នុងខ្លួនរបស់បុគ្គល ។ គេនិយាយពីសភាពផេងផោងនៃកំលាំងចិត្តចលករដែលកើតឡើងពីអាការៈនៃជំងឺក្នុងសរីរាង្គកាយ និង ប្រព័ន្ធសរសៃប្រសាទ ជាពិសេសគឺសំបកខួរក្បាលស្រទាប់ក្រោម ។ ជាការពិតណាស់ គេឃើញមានបណ្តុំសរសៃប្រសាទដ៏មានស្ថេរភាពទៅតាមកំរិតផ្សេងៗគ្នាដូចជា អស្ថេរភាពនៃបញ្ញា កំលាំងចលករ និង អត្តចរិតរបស់មនុស្ស ។ ក៏ប៉ុន្តែ នៅពេលដែលគេធ្វើការពិនិត្យវិភាគទៅលើណឺរ៉ូន(កោសិកាកាយសម្បទា) គេសង្កេតឃើញមានវិបល្លាសផ្លូវកាយ និង ផ្លូវចិត្តនៅក្នុងមជ្ឈមណ្ឌលសរសៃប្រសាទ ការតំរៀបគ្នានៃសរសៃប្រសាទ ហើយនិងតុល្យភាពនៃប្រព័ន្ធសរសៃប្រសាទនេះឯង ។ ក្នុងគ្រប់ករណីទាំងអស់ ប្រព័ន្ធសរសៃប្រសាទក្នុងខួរក្បាល និង ខួរឆ្អឹងខ្នង តែងតែមានការជាប់ពាក់ព័ន្ធគ្នាទៅតាមកំរិតយល់ដឹងរបស់បុគ្គលម្នាក់ៗ ។ នៅពេលម្តាយមានគភ៌ ឬនៅពេលដែលបុគ្គលប្រសូត្រចេញពីឧទរមាតា ហើយនៅពេលដែលបុគ្គលកើតមក មជ្ឈមណ្ឌលនៃសរសៃប្រសាទទាំងនេះ ស្តែងអោយឃើញនូវអស្ថេរភាពនៅក្នុងសរីរាង្គកាយខ្លះរបស់កុមារមួយចំនួន(1)។

រួមជាមួយក្រុមសរសៃប្រសាទទាំងនេះ គេសង្កេតឃើញមានសរសៃប្រសាទដែលមានភាពមិនទាន់រឹងមាំដែលធ្វើអោយមានភាពចុះខ្សោយនៃកំលាំងកាយ និង ចិត្ត ចំពោះកូនអ្នកញៀនស្រា ឬអ្នកកើតស្វាយប្រមេះ ដរាបណាដែលអ្នកបន្តពូជមិនមានភាពស្ថិតស្ថេរក្នុងខ្លួននោះ។ គេជួបប្រទះផងដែរនូវជំងឺអស្ថេរភាពដែលបណ្តាលមកពីជំងឺកង្វល់ផ្លូវចិត្តនៅក្នុងការអភិវឌ្ឍគ្រន្ថី (ជំងឺហៀរទឹកមាត់) ដែលធ្វើអោយបុគ្គលមានចរិតពិសេសមួយ (បេះដូងដើរញាប់, ញ័រចុងដៃចុងជើង, ញាក់ត្របកភ្នែក, ឈានទៅរកការចុះស្គមខ្លួនប្រាណ) ។នៅទីបំផុត ជំងឺប្រភេទនេះកំរកើតមានចំពោះកុមារណាស់ ប៉ុន្តែតាមទិដ្ឋភាពទូទៅជំងឺកង្វល់ខាងផ្លូវកាយនេះ នាំអោយកើតជំងឺកង្វល់ខាងផ្លូវចិត្តទៅតាមល្បឿនទូទៅរបស់ជំងឺនេះ គឺជំងឺញ័រញាក់ក្នុងខ្លួន ។ មុនដំបូង ជំងឺនេះធ្វើអោយប៉ះពាល់ដល់កំលាំងចលករខាងក្នុងខ្លួនដែលស្តែងចេញអោយឃើញនូវចលនាផ្សេងៗមិនទៀងទាត់ គ្មានរូបភាពពិតប្រាកដ អឆន្ទៈ គ្មានគោលដៅច្បាស់ ហើយមានការញ័រ និង កន្ត្រាក់សាច់ដុំឥតឈប់ឈរ សូម្បីតែកុមារដេកលក់ស្ងៀមធម្មតាក៏ដោយ ។ ភាពជាប់ទាក់ទងគ្នានេះ ចេះតែមានចលនាជាបន្ត ។ ជំងឺញាក់ញ័រនេះ កើតមានឡើងហាក់ដូចជាមានការប៉ះទង្គិច ឬមានសភាពឥតទៀងទាត់ក្នុងខ្លួនកុមារ ។

ដូចនេះគ្រូបង្រៀនម្នាក់ៗ ត្រូវស្វែងយល់ដឹងពីជំងឺផ្លូវចិត្ត និង ផ្លូវកាយរបស់កុមារម្នាក់ៗ ។ ករណីនេះ ទាមទារអោយគ្រូមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមគ្រួសារសិស្ស ។

---

*(1) Beley, O.C page 21*

ខ. **មូលហេតុបញ្ញារបស់កុមារ** : បញ្ញាមានតួនាទីសំខាន់ណាស់ ចំពោះកុមារដែលមានសភាពទន់ខ្សោយ និងកុមារដែលមានសភាពមិនឋិតថេរក្នុងខ្លួន ។ ជាការពិតណាស់ មានកុមារដែលទន់ខ្សោយកំលាំង ហើយដែលមានលក្ខណៈឋិតថេរដោយក៏រិតបញ្ញាលូតលាស់យឺតយ៉ាវ ។ លក្ខណៈបែបនេះធ្វើអោយបាត់បង់នូវចំណង់ចំណូលចិត្តរបស់កុមារដែលមានកំលាំងទន់ខ្សោយចំពោះភារកិច្ចនៃការសិក្សា ដែលមិនសមស្របទៅនឹងសុខភាពផ្ទាល់ខ្លួន ជាពិសេសនៅពេលដែលកុមារប្រភេទនេះ ឋិតនៅក្នុងថ្នាក់រៀនជាមួយមិត្តភក្តិស្រករវ័យ ការផ្ចង់ស្មារតីប្រុងប្រយ័ត្នស្តាប់គ្រូរបស់សិស្ស កំលាំងខ្សោយបែបនេះ មិនបានឋិតថេរក្នុងរយៈពេលយូរ ដូចសិស្សមានសុខភាពល្អមាំមួនទេ ។ លោក *Beley* បានបញ្ជាក់ពីអត្តចរិតរបស់សិស្សខ្សោយកំលាំងមិនឋិតថេរ និង មានការគិតមិនបាននឹងនរបែបនេះ ដោយលើកឡើងពីដំណើរយឺតយ៉ាវខាងផ្លូវចិត្ត និង បញ្ញា ហើយគាត់បានមានប្រសាសន៍ថា : "ករណីនេះ មិនមែនមកពីភាពមិនស៊ីសង្វាក់គ្នានៃប្រព័ន្ធសរសៃប្រសាទទេ ប៉ុន្តែប្រហែលជាបណ្តាលមកពីកង្វះកំលាំងចិត្តដ៏ស្អិតរមួតនៅក្នុងការសិក្សាតែម្តង" ។ លោក *E.Mounier* បានកត់សំគាល់ឃើញថា "កំលាំងចលករដ៏ទន់ខ្សោយ តាមធម្មតាមិនមែនចេះតែកើតឡើងនោះទេ ជួនកាលកំលាំងចលករបែបនេះ ធ្វើអោយកុមារមានកំលាំងរហិតរហៃនៅពេលដែលវាអង្គុយនៅស្ងៀម វាឈ្លីច្រមាមដៃទាំងពីរដោយចិត្តតប់ប្រមល់ ហើយភ្លេចភ្លាំងនូវបទបញ្ជាដែលគ្រូដាក់អោយ[(2)] ។

មូលហេតុនៃបញ្ញា ចំពោះជំងឺសតិអារម្មណ៍មិនឋិតថេរកើតមានផងដែរ ចំពោះកុមារដែលងាយស្តីប្រដៅ ហើយនិងកុមារដែលត្រូវអោយគ្រូប្រៀនប្រដៅតទៅទៀត ។ ម្យ៉ាងវិញទៀត ចំពោះកុមារប្រភេទជំងឺសតិអារម្មណ៍មិនឋិតថេរក៏កើតមានផងដែរ នោះគឺជំងឺយាយីសុខភាពចេះតែកើតមានតទៅទៀត ។ សម្បទាចលករនៅខាងក្នុងខ្លួនឋិតនៅក៏រិតទាបជាងសម្បទាបញ្ញា ហើយរចនាសម្ព័ន្ធនៃការសិក្សាចេះតែផ្លាស់ប្តូរជានិច្ច ។ ចំនុចអស់ទាំងនេះហើយ ដែលចូលរួមចំណែកធ្វើអោយមានភាពប្រែប្រួលនៃលំនឹងសុខភាពរបស់កុមារបន្តិចបន្តួច ជាពិសេសអ្នកដែលរស់នៅក្នុងមជ្ឈដ្ឋានជាមួយគ្នាតែងតែចាប់អារម្មណ៍ណាស់ចំពោះគុណភាពនៃការនិយាយស្តីរបស់កុមារទៅតាមកំលាំងចលករ និង កំលាំងបញ្ញា (សរសេរយឺត ហើយចេញតួអក្សរក្រវេមក្រវាម ហើយពិតជាមានប្រឡាក់ទឹកខ្មៅលើក្រដាសសៀវភៅ ប្រសិនណាជាកុមារប្រើស្លាបប៉ាកាជ្រលក់ទឹកខ្មៅ) ។ ប្រសិនណាជា គេមិនបានចាត់វិធានការដ៏សមស្របទេនោះ (ជាពិសេសគ្រូត្រូវក៏រិតផ្នែកកិច្ចការដែលតំរូវអោយសិស្សសរសេរ ហើយកិច្ចការបែបនេះត្រូវទំលាប់សិស្សអោយចេះប្រកាន់យកនូវសំណូមពរនៃការកែលំអជាធម្មតាផង) ចំពោះកុមារដែលកើតមានជំងឺសតិអារម្មណ៍មិនឋិតថេរ ។ ម្យ៉ាងវិញទៀត កុមារតែងតែស្តែងអោយឃើញនូវចរិតលក្ខណៈ និង ស្មារតីរហ័សរហួន ហើយកុមារខ្លះទៀតមានការផ្លាស់ប្តូរចិត្តគំនិតរហ័សជាងមិត្តភក្តិរបស់ខ្លួនទៅទៀត ។ នេះគឺជាគំលាតគ្នារវាងសម្បទាចលករដ៏ទន់ខ្សោយ និង សម្បទាបញ្ញាដែលកំពុងអភិវឌ្ឍក្នុងខួរក្បាល ហើយដែលអាចធ្វើអោយកុមារកើតមានជំងឺសតិអារម្មណ៍មិននឹងនរក្នុងខ្លួន ។ លក្ខណៈបែបនេះកំរកើតមានណាស់ នៅពេលដែលកុមារកំពុងរៀននៅក៏រិតបឋមសិក្សា ហើយលទ្ធផលនៃការយល់ដឹងរបស់គេមិនចុះខ្សោយឡើយ ។ ជួនកាលលទ្ធផលនៃការសិក្សាទៅជាទន់ខ្សោយ ហើយជាទូទៅលទ្ធផលនេះ ស្តែងចេញអោយឃើញនូវភាពមិនទៀងទាត់ផងដែរ ។

គ. **មូលហេតុសព្វេទនា** : ដែលគេអាចលើកយកមកនិយាយបានត្រង់ៗតែម្តង ច្រើនកើតមានចំពោះប្រភេទកុមារដែលឆាប់មានចិត្តរំភើប ឬមានទំនួលចិត្តឆាប់រន្ធត់ ។ ឧទាហរណ៍ : ការផ្លាស់ប្តូរគ្រូបង្រៀន ការដាក់ទណ្ឌ-

*(2) Beley, O.C page 446*

កម្មបានគ្រាន់តែធ្វើអោយកុមារមានទំនួលផ្លូវចិត្តឆាប់រន្ធត់ ហើយបង្កើតបាននូវសញ្ចេតនាដែលបាត់បង់នូវសុវត្ថិភាពក្នុងការសិក្សា ។ ចំពោះកុមារប្រភេទនេះ ត្រូវត្រូវរៀបចំអោយមានមជ្ឈដ្ឋានមួយ ដែលធានាបាននូវសុវត្ថិភាពផ្លូវចិត្ត និង ផ្លូវកាយចំពោះពួកគេ ។

មូលហេតុទាំងនេះ អាចឋិតនៅក្រោមរូបភាពមិនរវល់អើពើរបស់មនុស្សចាស់ ចំពោះការស្រឡាញ់ចូលចិត្តរបស់កុមារ ។ ចំពោះហេតុផលផ្សេងៗទៀត ចំណងទាក់ទងនៃការស្រលាញ់ចូលចិត្តរបស់កុមារ មិនមែនគ្រាន់តែកើតមានរវាងឪពុកម្តាយរបស់គេ និង ខ្លួនគេប៉ុណ្ណោះទេ ។ ការស្រលាញ់ចូលចិត្តនេះអាចកើតមានផងដែរ ចំពោះកុមារដែលជួបការលំបាកនៅក្នុងមជ្ឈដ្ឋានរស់នៅ ក្នុងដំណើរការបង្កើតបានជាសតិអារម្មណ៍ដ៏នឹងនរមាំមួនក្នុងខ្លួនគេ ។ "កុមារដែលទទួលការអប់រំមិនល្អក្នុងមជ្ឈដ្ឋានគ្រួសារ ក៏មានទំនួលផ្លូវចិត្តពីមជ្ឈដ្ឋានសង្គមមិនបានល្អដែរ" ។ នោះគឺបណ្តាលមកពីការលំបាកក្នុងការទប់រំញោច និង ការជំរុញទឹកចិត្តអោយធ្វើកិច្ចការណាមួយដែលត្រូវដាក់អោយធ្វើ ហើយស្តែងអោយឃើញនូវការលេចធ្លោឡើងពីជំងឺសតិអារម្មណ៍មិននឹងនរនេះឯង។ ដូច្នេះហើយបានជាលោក *J.Abramson* បានលើកឡើងពីការសង្កេតតាមដានចំនួន ៤ ដងទៅលើភាពវង្វេងស្មារតីដោយសារតែជំងឺ សតិអារម្មណ៍មិននឹងនរដែលកើតឡើងចំនួន ៥ ដងចំពោះកូនដែលកំព្រាឪពុក។ "ពេលមានសង្គ្រាម និង ពេលក្រោយសង្គ្រាម គេបានបំពេញតួនាទីមួយដ៏សំខាន់ដែលធ្វើអោយលេចធ្លោឡើងនូវរូបភាពនៃជំងឺសតិអារម្មណ៍មិននឹងនរនេះដោយសារការព្រាត់ប្រាសឪពុកម្តាយ ឬសមាជិកគ្រួសារ"(3) ។

មូលហេតុនៃសេចក្តីស្រលាញ់ ត្រូវឆ្លងកាត់តាមរយៈតួនាទីនៃបរិយាកាសអប់រំនៅក្នុងមជ្ឈដ្ឋានរស់នៅរបស់កុមារដែលងាយអោយកុមារចុះថយបាននូវជំងឺសតិអារម្មណ៍មិននឹងនរនេះ។ នៅមានករណីនៃការអប់រំដ៏រឹងកំព្រឹស ហើយទាំងបង្ខិតបង្ខំដែលកុមារត្រូវទទួលរង ហើយដែលកុមារត្រូវបត់បែនចិត្តគំនិតតាមផង។ ជាការពិតណាស់ កិរិយាមារយាទរបស់កុមារមានលក្ខណៈល្អឥតខ្ចោះ ។ ប៉ុន្តែពេលកុមារចូលរៀននៅក្នុងសាលា ដោយសារតែមានទំនាក់ទំនងជាមួយមិត្តភក្តិ ហើយមិនសូវមានអ្នកតាមដានកុមារអោយជិតដល់ផងនោះ ឬក៏នៅថ្ងៃណាមួយនោះ កុមារត្រូវទៅសំរាកវិស្សមកាលជាមួយមិត្តភក្តិ ហើយឋិតនៅឃ្លាតឆ្ងាយពីឪពុកម្តាយនោះ វាអាចមានបញ្ហាមួយកើតឡើង គឺកុមារមានលំងប់ចិត្តចំពោះតំរូវការនៃចលនាដ៏រស់រវើកនៃល្បែងកំសាន្តដែលកុមារមិនអាចបោះបង់ចោលបាន(4) ។ ក៏ប៉ុន្តែជាញឹកញយដងណាស់ គេតែងតែជួបប្រទះនូវករណីនៃបរិយាកាសដែលឪពុកម្តាយមិនអើពើនឹងកូន ធ្វើព្រងើយកន្តើយចំពោះកូនខ្វះសំណូមពរអប់រំ ខ្វះទំនួលខុសត្រូវលើកូន ខ្វះកិច្ចព្រមព្រៀងឯកភាពគ្នារវាងឪពុក និង ម្តាយទៅលើផែនការអប់រំ ឬបណ្តុះបណ្តាលកូនយ៉ាងណានោះ ឬក៏កូននោះឋិតនៅក្នុងករណីដែលឪពុកម្តាយបែកបាក់គ្នា ។ លោក *Beley* បានអះអាងថា : "កុមារ និង ក្មេងជំទង់ខ្លះ ច្រើនតែកើតជំងឺសតិអារម្មណ៍មិននឹងនរ តែនៅពេលណាដែលការអប់រំរបស់គេមានភាពទូលំទូលាយពេក ហើយមិនសមស្របទៅតាមការស្រេកឃ្លាននៃចំណង់ចំណូលចិត្តរបស់កុមារនៅពេលណាមួយនោះ" ហើយចូលមកដល់ឆ្នាំ១៩៥១ទៅហើយ លោក *Beley* បានវាយតំលៃថា : "គេមិនត្រូវទំលាក់កំហុសធ្ងន់ទៅលើគ្រួសារដែលមានកុមារកើតជំងឺសតិអារម្មណ៍មិននឹងនរនោះទេ ។ ឪពុកម្តាយត្រូវឋិតនៅក្នុងលក្ខខណ្ឌដែលបង្ខំចិត្តអោយរកស៊ីចិញ្ចឹមកូន" ។ លើគ្រប់ករណីទាំងអស់ គេសង្កេតឃើញថា ការបែកបាក់ឪពុកម្តាយ និង ការឃ្លាតឆ្ងាយពីក្របខណ្ឌជីវវប្បធម៌ កើតមានចំពោះកុមារចំនួនជាងពាក់កណ្តាល ចំពោះករណីកុមារដែលមានជំងឺបាក់កំលាំងកាយ ហើយពាក់

*(3) Beley, O.C page 68 & 75, (4) Beley O.C page 103*

ព័ន្ធទៅនឹងជំងឺសតិអារម្មណ៍មិននឹងនរនេះ ។ ចំនែកឯពួកកុមារដែលមានជំងឺវិបល្លាសសតិអារម្មណ៍វាយមាយច្រើនតែជាកូនដែលឪពុកម្តាយមានកិរិតវប្បធម៌ទន់ខ្សោយ ក្នុងការអប់រំកូនអោយមានគំនិតផ្ទុយពីវប្បធម៌ជឿនលឿននោះឯង(5) ។

**ឃ. <u>មូលហេតុសរីរាង្គកាយ</u>** : មូលហេតុនៃជំងឺសរីរាង្គកាយ អាចបង្កអោយមានការលេចធ្លោឡើងនូវជំងឺប្រកបដោយគ្រោះថ្នាក់ ឬក៏ធ្វើអោយអ្នកអាណាព្យាបាលមានការព្រួយបារម្ភនៅក្នុងប្រការដែលបាតុភូតត្រូវគេលើកយកមកសិក្សាស្រាវជ្រាវនេះ ត្រូវគេចាត់ទុកថា ជាជំងឺម្យ៉ាងដែលកើតឡើងពិត។ ហើយមិនគេចផុតពីភាពអពមង្គលក្នុងគ្រួសារកុមារ ។ មានកុមារមួយក្រុមដែលចូលចិត្តគ្រាប់តាមបងធំបងតូច ហើយគេចមិនចូលរៀនក្នុងថ្នាក់ ដើម្បីទៅដើរលួចឆក់ ។ លោក *Heuyer* បានប្រើពាក្យថា ជំងឺអស្ថេរភាពក្នុងសរីរាង្គកាយផ្សេង។ពីគ្នា ដូចជាជំងឺបាក់កំលាំងចលករដែលស្តែងឡើងអោយឃើញថា កុមារមានដំណើរការយឺតយ៉ាវក្នុងមុខងារនៃកំលាំងចលករ ឬក៏សរីរាង្គចលកររបស់កុមារមិនមានដំណើរការស៊ីសង្វាក់គ្នាសោះ តាំងពីពេលដែលកុមារនោះកើតមកពីឧទរមាតាដូចជា : ការដើរបោះជំហាន, ការចេះនិយាយស្តីពាក្យមួយម៉ាត់។, ការនិយាយស្តីអោយគេស្តាប់បាន និង អនាម័យក្នុងការរស់នៅ ។ តាមគំនិតរបស់លោក *Beley* លោកបានលើកឡើង ពីអត្តចរិតរបស់កុមារដែលកើតមានជំងឺសតិអារម្មណ៍មិននឹងនរ ដើម្បីបង្ហាញអោយឃើញពីករណីដែលកត្តានានានៃជំងឺសរីរាង្គកាយត្រូវបានកំនត់ជាស្រេច ហើយបង្កអោយមានអត្ថិភាពតែមួយគត់គឺ "ភាពវាយមាយ" ។ ម្យ៉ាងវិញទៀត លោក *Beley* បានធ្វើការវែកញែកដូចលោក *J.Abramson* ដែរ គឺជំងឺវង្វេងស្មារតី និង សតិអារម្មណ៍ ជំងឺវិបល្លាសសតិអារម្មណ៍, ជំងឺឡប់ស្មារតី, ជំងឺឆ្កួតជ្រូក, ជំងឺស្មារតីវាយមាយ, ជំងឺសរីរាង្គកាយ និង ជំងឺផ្លូវចិត្ត ។ នៅគ្រប់ករណីទាំងអស់ គេអាចនិយាយបានថា ÷ ទស្សនៈរបស់លោក *Beley* គឺ "ដំណោះស្រាយឋិតនៅក្នុងកណ្តាប់ដៃនៃក្រុមការងារស្រាវជ្រាវមួយដែលមិនទាន់ចេញជាពន្លឺច្បាស់ ហើយដែលកំពុងស្រាវជ្រាវពីកុមារដែលមានសុខភាពផ្លូវចិត្តល្អ ហើយដែលរួមមានទាំងគ្រូពេទ្យផ្នែកចិត្តរោគ ជំនួយសង្គម និង ជំនួយការខាងចិត្តសាស្ត្រផងនោះ"(6) ។

ទីបំផុត បើគេស្ថិតនៅក្នុងជ្រុងមួយនៃទស្សនៈដ៏ត្រឹមត្រូវ គេសង្កេតឃើញថា : កុមារដែលមានចិត្តឆាប់ខឹងឆេវឆាវ ច្រើនកើតជំងឺសតិអារម្មណ៍មិននឹងនរដែលគេច្រើនហៅថា "ពួកខូចសរសៃប្រសាទ" ។ លោក *A.Le Gall* បានសរសេរថា : "កុមារកើតមកមានលក្ខណៈវពីសដូចកុមារមានជំងឺសតិអារម្មណ៍មិននឹងនរ ។ អ្នកផងចូលចិត្តនៅក្បែរកុមារណាស់ ហើយដោយកុមារមានចំណង់ចំណូលចិត្តមិនស្ថិតស្ថេរគួរអោយកុមារមានឱកាសច្រើនណាស់សំរាប់អោយគេបំភ្លេចចោលបានទៅតាមការស្តែងចេញនូវកិរិយាមារយាទរបស់គេ ។ កុមារអាចធ្វើការ ឬលេងកំសាន្តបានដរាបណាដែលចំណង់ចំណូលចិត្តរបស់គេស៊ីសង្វាក់គ្នាជាមួយឱកាសដែលហុចអោយប៉ុណ្ណោះ(7) ។

សរុបមក គ្រូបង្រៀនត្រូវស្វែងយល់ពីភាពវាយមាយ និង ជំងឺផ្លូវចិត្ត ផ្លូវកាយរបស់កុមារដែលបណ្តាលមកពីកត្តាទាំង ៤ យ៉ាងនេះ ។ ខ្លឹមសារនៃការបង្រៀន និង ការអប់រំត្រូវអោយមានលក្ខណៈសមស្របទៅតាមបុគ្គលិកលក្ខណៈសិស្សដែលខ្លួនគ្រប់គ្រង ជាពិសេសការអប់រំទៅលើប្រភេទដូចបានពិពណ៌នានេះ ។

បណ្ឌិត : **ចាន់ រដ្ឋសុផា**

(5) *Beley O.C page 75*, (6) *Beley O.C page 76*, (7) *A.Le Gall & Beley O.C page 56*

# ការកសាងកម្មវិធីបណ្ដុះបណ្ដាលបុគ្គលិក

**១. ការបណ្ដុះបណ្ដាលជាអ្វី?**

ការបណ្ដុះបណ្ដាលបុគ្គលិកនៅក្នុងអង្គភាពមួយ គឺជាកិច្ចការរៀបចំតាមផែនការល្អិតល្អន់ និង ជាលក្ខណៈប្រព័ន្ធដើម្បីលើកស្ទួយចំណេះដឹងជំនាញរបស់បុគ្គលិក និង ដើម្បីផ្លាស់ប្ដូរ ឬបង្កើនគំរូឥរិយាបថ និង ការប្រព្រឹត្តដែលគេត្រូវការសំរាប់បំពេញការងារដែលអង្គភាពប្រគល់ជូនអោយបានជោគជ័យ ។

ការបណ្ដុះបណ្ដាលត្រូវបានបង្កើតឡើង តាមការរៀបចំក្នុងអង្គភាពដូចខាងក្រោម ÷

**ក- កែលំអផលិតភាព:**

អាចអោយគ្រូបង្រៀននិងបុគ្គលិករដ្ឋបាលបំពេញការងាររបស់ខ្លួនអោយមានប្រសិទ្ធភាពថែមទៀត។

**ខ- បង្កើនការងារបច្ចុប្បន្នអោយមានប្រសិទ្ធភាព:**

ជួយដល់គ្រូបង្រៀន និង បុគ្គលិករដ្ឋបាលទាំងអស់ ដើម្បីកែលំអ ឬបង្កើនសមត្ថភាពជំនាញ និង ចំណេះ ដឹងរបស់ពួកគេ។

**គ- លើកស្ទួយសមត្ថភាពបំពេញការងារ:**

រៀបចំគ្រូ និង បុគ្គលិករដ្ឋបាលសំរាប់អនុវត្តការងារថ្មី ឬមុខតំណែងថ្មីដែលអាចជាការងារពិបាកជាងមុន ឬខ្ពង់ខ្ពស់ជាងមុន ។

**ឃ- ជំរុញស្មារតី:**

កែលំអគ្រូ និង ឥរិយាបថបុគ្គលិករដ្ឋបាលចំពោះការងារ កម្មករ អ្នកត្រួតពិនិត្យ និង អង្គភាពទាំងមូល ។

**២. ជំហានក្នុងលំនាំនៃការកសាងផែនការបណ្ដុះបណ្ដាល:**

ជំហានទាំងឡាយក្នុងលំនាំនៃការងារកសាងផែនការបណ្ដុះបណ្ដាលរួមមាន ÷

**ក- ការកំណត់តំរូវការបណ្ដុះបណ្ដាល:**

ដើម្បីកំណត់តំរូវការបណ្ដុះបណ្ដាល គេបានវិភាគលើកត្តាខាងក្រៅ និង កត្តាខាងក្នុង រួចគេក៏បានជ្រើសរើសប្រភព និង វិធីផ្សេងៗដើម្បីកំណត់ពីតំរូវការបណ្ដុះបណ្ដាលនោះ ។

**ខ- ការកំណត់អាទិភាពតំរូវការបណ្ដុះបណ្ដាល:**

បញ្ហានេះទាក់ទងធ្វើសេចក្ដីសំរេចចិត្ត ដើម្បីបង្កើតអាទិភាពសំរាប់ការបណ្ដុះបណ្ដាល ។ ការសំរេចចិត្តត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ។

**គ- ការកំណត់លើវត្ថុបំណងបណ្ដុះបណ្ដាល:**

វត្ថុបំណងនៃកម្មវិធីបណ្តុះបណ្តាលត្រូវបង្ហាញពីអ្វីដែលសិក្ខាកាមត្រូវការសិក្សា និង លទ្ធផលពីការសិក្សានោះ ។

**ឃ- ការធ្វើគំរោងផែនការបង្រៀនៈ**

ខ្លឹមសារមេរៀនត្រូវបានជ្រើសរើស និង ដាក់ជាលំដាប់សំរាប់បង្រៀនដោយផ្អែកលើវត្ថុបំណងសិក្សាច្បាស់លាស់ដែលបញ្ជាក់ពីលក្ខខណ្ឌចំណេះដឹង និង បទពិសោធន៍របស់អ្នកសិក្សា ។ ចំពោះវត្ថុបំណងបណ្តុះបណ្តាលនីមួយៗ យើងត្រូវជ្រើសរើសវិធីអោយបានសមស្រប ដើម្បីសំរេចបាននូវលទ្ធផលសិក្សាដែលបានគ្រោងទុក ។ យើងក៏ត្រូវជ្រើសរើស និង កសាងសំភារៈ បង្រៀន និង កំណត់ពីសមាសភាគវាយតំលៃផងដែរ ។ ទ្រង់ទ្រាយសមស្របទាំងឡាយត្រូវបានជ្រើសរើសសំរាប់សកម្មភាព សិក្សា និង សំរាប់កាលវិភាគបង្រៀនរបស់ពួកគេ ។

គ្រូមួយចំនួនត្រូវការអនុវត្តសកម្មភាពផ្សេងៗគ្នាដែលគេបានកំណត់រួចហើយ ក្រោយមកគ្រូទាំងនេះក៏ត្រូវជ្រើសរើសដែរ ។

**ង- ការកំណត់ពីរបៀបសំរបសំរួលសំភារៈប្រើប្រាស់ចំពោះព្រឹត្តិការណ៍ដែលកើតមានៈ**

បញ្ហានេះ រួមមានការជ្រើសរើសសំភារៈប្រើប្រាស់ បទដ្ឋានគ្រប់គ្រងសំរាប់ការគ្រប់គ្រងកម្មវិធី និង ការកសាងបទដ្ឋានណែនាំផ្សេងៗ ។ វាក៏មានសំភារៈសំខាន់ផងដែរ ដើម្បីផ្តល់ប្រព័ន្ធត្រួតពិនិត្យកម្មវិធី និង ការធ្វើសេចក្តីសំរេចចិត្តនៅពេលមានការផ្លាស់ប្តូរកម្មវិធី ។

**ច- ការធ្វើគំរោងបែបបទវាយតំលៃៈ**

យើងត្រូវបញ្ជាក់អោយច្បាស់ពីទំរង់បែបបទនៃការវាយតំលៃ និង កំណត់របៀបប្រមូលទិន្នផល ។ ឧទាហរណ៍ : ឆ្លងតាមរយៈការប្រលងការប្រើតារាងសំនួរ និង ការធ្វើសំភាសន៍-ល-

យើងត្រូវកំណត់របៀបវិភាគទិន្នន័យ និង របៀបប្រើទិន្នន័យសំរាប់ធ្វើអនុស្សរណៈ និង សេចក្តីណែនាំផងដែរ ។ម្យ៉ាងទៀត យើងត្រូវដំណើរការវិភាគក្រុមមុខសញ្ញាដោយការកំណត់លើជីវប្រវត្តិសញ្ញាប័ត្រ និង បទពិសោធន៍របស់ក្រុមមុខសញ្ញានោះ ។

**ឆ- ការរៀបចំថវិកា និង ផែនការទីផ្សារៈ**

បញ្ហានេះ ទាក់ទងជាដំបូងលើការប៉ាន់ស្មាន ការចំណាយលើកម្មវិធីបណ្តុះបណ្តាលរួមមានតំលៃសំរាប់កសាងកម្មវិធីដំណើរការកម្មវិធី និង ការវាយតំលៃកម្មវិធី ។

ឧទាហរណ៍ : ប្រាក់ឧបត្ថម្ភមន្ត្រី ប្រាក់ខែ ប្រាក់ចំណាយលើសិក្ខាកាម ការជួលសំភារៈបរិក្ខាប្រើប្រាស់ទីកន្លែងបណ្តុះបណ្តាល និង ការចំណាយលើសំភារៈបង្រៀន ។ល ។

បន្ទាប់មក យើងត្រូវកំណត់អោយបាន តើកម្មវិធីនឹងត្រូវផ្តល់ប្រាក់បែបណា ? ឧទាហរណ៍ : ការផ្តល់ប្រាក់តាមរយៈការបង់ថ្លៃសិក្សារបស់សិក្ខាកាម ការផ្តល់ប្រាក់របស់រដ្ឋាភិបាល ឬការផ្តល់ប្រាក់ពីភ្នាក់ងារផ្សេងៗទៀត ។

ទីបញ្ចប់ យើងត្រូវជ្រើសរើស និង រៀបចំឯកសារផ្សព្វផ្សាយដូចជាកូនសៀវភៅ និង ការធ្វើយុទ្ធនា

ការផ្សព្វផ្សាយក្នុងកាលវេលាសមស្រប ដើម្បីទាក់ទាញរកថវិកាសំរាប់កម្មវិធីបណ្ដុះបណ្ដាលនោះ ។

**៣. សេចក្ដីសន្និដ្ឋាន**

គ្មានវិធីណាងាយដើម្បីកសាងកម្មវិធីបណ្ដុះបណ្ដាលបុគ្គលិកអោយបានជោគជ័យនោះទេ ។ កត្តាសំខាន់គឺយើងត្រូវដឹងពីជំហានផ្សេងៗដែលទាក់ទងនឹងការកសាងកម្មវិធីបណ្ដុះបណ្ដាល ដើម្បីអោយស្របទៅនឹងតំរូវការរបស់អង្គភាពរួមមានទាំងបរិយាកាសខាងក្រៅ និង បរិយាកាសខាងក្នុងអង្គភាព ។ នេះអាចជួយក្នុងការអនុវត្តអោយកម្មវិធីអភិវឌ្ឍបុគ្គលិកកាន់តែមានទំនាក់ទំនង និង មានសារៈសំខាន់ដល់អង្គភាព ។ លើសពីនេះទៅទៀតយើងត្រូវស្គាល់ និង យល់អោយច្បាស់ពីប្រភព និង វិធីដើម្បីកំណត់តំរូវការបណ្ដុះបណ្ដាលវិធីផ្សេងៗក្នុងដំណើរការវិភាគតំរូវការបណ្ដុះបណ្ដាលវត្ថុបំណងនៃការបណ្ដុះបណ្ដាលខ្លឹមសារ និង វិធីសាស្ត្រ ហើយនិងទំរង់ការសំរបសំរួលការងារ ។

បញ្ហាផ្សេងៗទៀតដែលយើងគួរយកចិត្តទុកដាក់ គឺការវាយតំលៃកម្មវិធីបណ្ដុះបណ្ដាលការសរសេររបាយ-ការណ៍វាយតំលៃ និង ការរៀបចំថវិកាសំរាប់កម្មវិធីបណ្ដុះបណ្ដាល ។ នេះគឺជាវិធីដ៏សក្តិសមមួយសំរាប់ដំណើរការកម្មវិធីបណ្ដុះបណ្ដាលប្រកបដោយជោគជ័យ ។

លោក : ឆេង ឡឿន

ប្រធានការិ.អប់រំ និង គ្រប់គ្រង

នៃមហាវិទ្យាល័យគរុកោសល្យ

"ការអប់រំ គឺជាអាវុធដែលមានអានុភាពខ្លាំងក្លាបំផុត ដើម្បីផ្លាស់ប្ដូរពិភពលោក"

ណែលសុន ម៉ិនដឺឡា

"L'éducation est l'arme la plus puissante pour changer le monde"

Nelson Mandela




# សតវត្សវិទ្យាសាស្ត្រ និង បច្ចេកទេស

# ១៨៦០ ~ ១៩៦០

**១៨៦០ ~ ១៩៦០ ជាសតវត្សមួយ :**

- ដែលបានចាប់ផ្ដើមពីការបង្កើតម៉ូទ័របន្ទុះ (moteur à explosion) របស់លោក អេជែន ឡឺន័រ (១៨៦០ Etienne Lenoir) ហើយបញ្ចប់ដោយការហោះហើរទៅកាន់អវកាសរបស់មនុស្សទី១ (១៨៦០) ។
- នៃរបកគំហើញវិទ្យាសាស្ត្រ និង ការបង្កើតបច្ចេកទេសដែលបានផ្លាស់ទ្រង់ទ្រាយពិភពលោកដែលមិនធ្លាប់មានរាប់លានឆ្នាំមកហើយ តាំងពីការចាប់កំនើតមនុស្សលើផែនដី ។
- ដែលគេអាចនិយាយបានថា ជាពេលវេលារត់លឿន និង ប្រវត្តិសាស្ត្របង្កើនល្បឿន ។

យ៉ាងនេះ ប្រសិនបើគេអាចផ្ទៀងផ្ទាត់លើគ្រប់វិស័យនោះ គេកត់សំគាល់ឃើញថា វាជាមុខវិជ្ជាដែលបានធ្វើ វិភាគទានជាពិសេសដល់បដិវត្តន៍នៃរបបរស់នៅ និង ចិត្តគំនិត ។ ដូចនេះ ឈរតាមការសិក្សារចនាសម្ព័ន្ធល្អិតបំផុតនៃរូបធាតុ (ពិសេសបរមាណូ) រូបវិទ្យាទំនើបដែលវិវត្តចាប់ពីចុងសតវត្សមុន ហើយជាអាទិ៍មានអ្នកប្រាជ្ញដូចជាព្យែរ និង ម៉ារីគួរី (Pierre et Marie Curie) គឺជាឫសគល់អភិវឌ្ឍន៍ និង អនុវត្តន៍ដោយឥតព្រំដែន ។

**របកគំហើញស្វ័យត :**

១៨៩៨ : ព្យែរ និង ម៉ារីគួរី (Pierre et Marie Curie) រកឃើញរ៉ាដ្យូម

១៩០៥ : អាល់បែរ អែនស្ទែន (Albert Einstein) កសាងទ្រឹស្ដីសាបេក្ខភាព (ភាពអាចប្រែប្រួលបាន : Théorie de la Relativité)

១៩១៤ - ១៩១៨ : សង្គ្រាមលោកលើកទី១

១៩២៦ : ជន បែត (John Baird) សំរេចការផ្សាយតាមទូរទស្សន៍លើកទី ១

១៩២៨ : អាឡេចសង់ ហ្វ្លេមីង (Alexander Fleming) រកឃើញថ្នាំប៉េនីស៊ីលីន

១៩៣៤ : ហ្វ្រេដេរិច និង អ៊ីរ៉ែន ជូលីយ៉ូ-គួរី (Frédéric et Irene Joliot-Curie) រកឃើញវិទ្យុសកម្មនិមិត្ត

១៩៣៩ - ១៩៤៥ : សង្គ្រាមលោកលើកទី ២

១៩៤៥ : ការទំលាក់គ្រាប់បែកបរមាណូនៅហ៊ីរ៉ូស៊ីម៉ា (ជប៉ុន)

១៩៥១ : ការបង្កើតមណ្ឌលនុយក្លេអែរទី១

១៩៦១ : យូរី កាការីន គឺជាមនុស្សទី១ ដែលហោះហើរក្នុងអវកាស

ប្រែសំរួលដោយ : **កែវ យ៉ារ**

# ម៉ាស៊ីនងាយៗ

## ឃ្នាស់ដែលបុព្វបុរសយើងបានប្រើប្រាស់តាំងពីយូរយារមកហើយនោះ គឺជាម៉ាស៊ីនដំបូងបង្អស់...

ពីរ៉ាមីតដ៏ធំមហិមារបស់ស្តេច *Chéops* មានកំពស់ ១៤៧ ម៉ែត្រ ប្រើប្រាស់ថ្មអស់ប្រមាណ ៥លានតោន ។ តើមនុស្សកាលពីសម័យ ៤៥០០មុន ខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីសាងសង់អោយសំរេចបាននូវអច្ឆរិយវត្ថុដ៏ធំសំបើម ទៅតាមរូបភាពគណិតវិទ្យាសុទ្ធសាធយ៉ាងនេះ ?

ជាការពិតណាស់ប្រវត្តិវិទូ *Hérodote* បានរាយការណ៍បញ្ជាក់ហើយថា នៅពេលដែលប្រទេសពែកក្តាប់អំណាចគ្រប់គ្រង កំលាំងពលករនៅអេស៊ីប និង អាហ្វ្រិចខាងកើតចំនួន ២០០.០០០នាក់ បានធ្វើការកសាងនោះអស់រយៈពេលជាងពីរឆ្នាំ ។

បើនិយាយពីបច្ចេកទេសនៃការសាងសង់វិញ ចាប់តាំងពីពេលនោះ រហូតមកដល់បច្ចុប្បន្ននេះ ពុំមានការវិវត្តអ្វីជាដុំកំភួនឡើយ ឬថាវិវត្តរីកចំរើនដែរ តែតិចតួចប៉ុណ្ណោះ ។ ពិតណាស់ សំភារៈសំណង់ឥឡូវទំនើបៗអាចបង្កើនកំលាំងធន់ទ្រ និង អនុភាពផ្សេងៗទៀតជាច្រើន តែចំពោះគោលការណ៍ទាំងឡាយនៃសំណង់ វានៅតែជាសញ្ញាណនៃមូលដ្ឋានមេកានិចដដែល ហើយនឹងស្ថិតនៅបែបនេះតទៅទៀត គ្មានប្រែប្រួលឡើយ ។

រូបវិទូទីមួយ ដែលមានគំនិតប្រឌិតញាណក្នុងការធ្វើអនុមានច្បាប់នៃទ្រឹស្តីម៉ាស៊ីន ហើយដែលបានប្រើប្រាស់តាំងពីសម័យបុរាណយូរលង់មកហើយនោះ គឺលោក *Archimède* (២៨៧-២១២ មុនគ.ស) ។ លោកបានបញ្ចេញគំនិតមួយថា លោកនឹងអាចគាស់លើកផែនដីនេះបាន បើសិនជាមានគេអោយចំណុចកំណល់មួយដល់គាត់ ។ ជាផលរួមនៃបទពិសោធន៍ និង អច្ឆរិយញាណរបស់លោក យើងបានបរិធានមួយដែលសព្វថ្ងៃយើងតែងតែកាន់ប្រើប្រាស់ដោយគ្មានបានគិតគូរផង នោះគឺឃ្នាស់ ។

ឃ្នាស់ត្រូវបានគេប្រើប្រាស់ទៅតាមទំរង់រូបភាពផ្សេងៗជាច្រើន តែនៅក្រោមគោលការណ៍រួមមួយគឺ : ដងមួយរឹងមាំ អាចវិលជុំវិញចំណុចកំណល់នឹងមួយ ដែលស្ថិតនៅក្នុងចំងាយណាមួយពីចុងសង្ខាងនៃដងនោះ ។




ចុងម្ខាងនៃដង ជាចំណុចប្រើកំលាំង ឯទំងន់ដែលត្រូវលើក ស្ថិតនៅឯចុងម្ខាងទៀត ។ ជាទូទៅចំណុចប្រើកំលាំង និង ចំណុចទំងន់ ស្ថិតនៅប្រហាក់ប្រហែលក្នុងជួរជាមួយគ្នានឹងចំណុចកំណល់ ។ ឃ្នាស់ខ្លះបែបធម្មតាដូចជាដងស្នប់អណ្តូងទឹក ប្រដាប់គាស់សំបកកង់... ខ្លះទៀតមានបែបជាគូរដូចជា កន្ត្រៃ ប្រណាក ដង្កាប់... ។

បើសង្កេតទៅលើទីតាំងនៃចំណុចកំណល់ គេអាចបែងចែកឃ្នាស់ជាបីប្រភេទ :

១- ចំណុចកំណល់នៅចន្លោះកំលាំង និង ទំងន់ដូចជា កូនរទេះលើកដាក់បាវ អង្ករ...

២- ទំងន់នៅចន្លោះកំលាំង និង ចំណុចកំណល់ដូចជា រទេះរុញ ប្រណាក... ជាដើម

៣- កំលាំងនៅចន្លោះទំងន់ និង ចំណុចកំណល់ដូចជា ដង្កៀបចាប់ទឹកកក ឈ្នាន់បង្វិល ថ្មសំលៀង... ។



## កង់មូល និង តំណពូជពង្ស...

ការច្នៃប្រឌិតទំរាំបង្កើតបានជាកង់មូលយកទៅធ្វើរ៉ក មានប្រវត្តិតាំងពីយូរយារណាស់មកហើយ ក្នុងយុគសម័យដែលកប់បាត់ងងឹតឈឹងដោយពេលវេលា ។ ដំបូងឡើយ កង់ជាដុំឈើបួនជ្រុង រួចចាំងលុបជ្រុងខ្លះៗនៅបែបកំរោល ស្ថិតនៅនឹងថ្កល់ រួចមកទើបចល័ត អាចវិលជុំវិញអ័ក្សមួយ ។ ដុំឈើនោះ បានផ្លាស់ប្ដូររូបរាងបន្តិចម្ដងៗ យូរណាស់ទំរាំបានប្រែក្លាយមកជាកង់មូលរំលីងយ៉ាងស្អាត ប្រកបដោយចង្អូរសំរាប់អោយខ្សែពួរ ឬខ្សែកាបអូសកាត់បាន ។

គេប្រើរ៉កសំរាប់យោងឥវ៉ាន់ ដោយដាក់របស់នៅចុងខ្សែម្ខាង ហើយប្រើកំលាំងទាញនៅចុងម្ខាងទៀត ។ គេផ្គុំរ៉កច្រើនលើអ័ក្សមួយបានជាក្រុមរ៉ក ហើយគេប្រើក្រុមរ៉កពីរធ្វើជាកៅឡាក់(១) ។ គេធ្វើយ៉ាងនេះ ព្រោះកំលាំងបានត្រូវកាត់បន្ថយសមាមាត្រទៅនឹងចំនួនខ្សែ ឬចំនួនរ៉កដែលកៅឡាក់នោះមាន ។

នៅសម័យទំនើបយើងនេះ ឧបករណ៍ប្រើប្រាស់ផ្សេងៗត្រូវបានផលិតអំពីលោហធាតុអស់ហើយ ។ រ៉កឈើមាននៅសល់ប្រើខ្លះ តែសំរាប់ទូកក្ដោងកំសាន្ដប៉ុណ្ណោះ ក្រៅពីនោះកង់ផ្សេងៗត្រូវបានផ្លាស់ប្ដូរជាកង់មានស្ពឺដែលផ្ដល់ទិន្នផលបានខ្ពស់ជាង ។ តែបើនិយាយពីច្បាប់មេកានិកវិញ ពុំមានអ្វីផ្លាស់ប្ដូរទេ ចាប់តាំងពីពេលដែលគេបានរកឃើញរ៉កដំបូងមកនោះ ។ ម៉ាស៊ីនទំនើបៗក៏នៅតែអនុវត្តច្បាប់មេកានិកដដែលនេះដូចគ្នា ។

ឃ្នាស់ និង កង់មូលនេះហើយ ជាម៉ាស៊ីនដំបូងបង្អស់របស់មនុស្សជាតិ ។

ប្រែសំរួលដោយ : **យស់ អ៊ាង**

*Encyclopédie des connaissances actuelles.*

(១) គឺប្រដាប់ទាញដោយដៃ រឺខ្សែកាបទាញដោយម៉ូទ័រៈ *palan*




## ភាសា

# ការប្រើប្រាស់រាជស័ព្ទក្នុងសង្គមខ្មែរ

ប្រទេសកម្ពុជា ជាប្រទេសមួយមានវ័យចំណាស់ជាងគេក្នុងតំបន់ ។ ប្រទេសនេះបានបន្សល់នូវភស្តុតាងជាកេរមរតកជាច្រើនដែលបញ្ជាក់ថា ទឹក ដី វប្បធម៌ ភាសា អក្សរសាស្ត្រ ប្រពៃណី ទំនៀមទំលាប់ សាសនា រដ្ឋបាលរបស់ខ្លួនមានអាយុកាលដ៏យូរអង្វែង ហើយបានចាក់ឫសយ៉ាងជ្រៅជ្រាបចូលក្នុងសង្គមខ្មែរគ្រប់វិស័យ ។ សង្គមខ្មែរបានប្រកាន់យករបបរាជានិយមចាប់ពីសតវត្សទី ១ ។ របបនេះ បានធ្វើអោយសង្គមខ្មែរមានការរីកចំរើនលើគ្រប់ផ្នែកក្នុងការកសាងប្រទេសជាតិដូចជា កសិកម្ម សេដ្ឋកិច្ច គមនាគមន៍ វប្បធម៌ ។

ភាសាជាមធ្យោបាយមួយសំរាប់ធ្វើគមនាគមន៍រវាងមនុស្ស និង មនុស្សក្នុងសង្គម ។ ភាសាមានការប្រែប្រួលឥតឈប់ឈរពីសម័យមួយទៅសម័យមួយ ។ ភាសាមានកំណើតដំណាលគ្នានឹងកំណើតសង្គមមនុស្ស ហើយវាមានការបែងចែកតាមវណ្ណៈ ឋានៈ វ័យ ពណិសំបុររបស់មនុស្សក្នុងសង្គម ។ រាជស័ព្ទ ជាភាសាមួយដែលគេប្រើប្រាស់សំរាប់ទាក់ទងរវាងក្រុមរាជវង្សានុវង្ស និង មនុស្សទូទៅ(រាស្ត្រ) ។ រាជស័ព្ទមានកំណើតក្នុងសង្គមខ្មែរ ចាប់ពីសតវត្សទី ១ មកម្ល៉េះ ÷

### ក. ពាក់ព័ន្ធនឹងរាជវង្សានុវង្ស

| រាជស័ព្ទ | ភាសាសាមញ្ញ |
|---|---|
| ខត្តិយត្រកូល | ត្រកូលស្តេច |
| អយ្យកាទួត ឬមហយ្យិកា | ជីដូនទួត |
| មហយ្យិកោ ឬអយ្យកោទួត | ជីតាទួត |
| អយ្យកា | ជីដូន |
| សស្សូ ឬសន្ទិយា | ម្តាយក្មេក |
| រាជាយាសិត | មហេសី ឬប្រពន្ធ |
| បិតុលា | មា ឬឪពុកធំខាងឪពុក |

| រាជស័ព្ទ | ភាសាសាមញ្ញ |
|---|---|
| អយ្យកោ | ជីតា |
| ព្រះបិតា | ឪពុក |
| ព្រះមាតា | ម្តាយ |
| សសុរៈ | ឪពុកក្មេក |
| ស្វាមី ឬភស្តា | ប្តី |
| បិតុច្ឆា | មីង ឬម្តាយធំខាងឪពុក |
| ភគវតី | អគ្គមហេសីនៃស្តេច ទ្រង់រាជ |

| | |
|---|---|
| ភគិនីភស្តា | ប្តីរបស់បងស្រីឬប្តីរបស់ប្អូនស្រី |
| មាតុច្ឆា | ម្តាយមីង ឬម្តាយធំខាងមាតា |
| ជេដ្ឋភាតា | បងប្រុស |
| ភាតា | បងប្រុស ឬប្អូនប្រុស |
| ឱរស | កូនប្រុស |
| សុណិសា ឬសុណ្ហា | កូនប្រសាស្រី |
| កនិដ្ឋភាតា | ប្អូនប្រុស |
| ភាគិនេយ្យ | ក្មួយស្រី |
| រាជកុមារ | រាជបុត្រវ័យក្មេង |
| រាជតនយា | បុត្រី ឬកូនស្រី |
| រាជទារក | កូនង៉ែតប្រុស |
| រាជទាយាទ | កូនដែលត្រូវទទួលបន្តវង្ស |

| | |
|---|---|
| មាតុលា | ឪពុកមា ឬឪពុកធំខាងមាតា |
| ភគិនី | បងស្រី ឬប្អូនស្រី |
| ជេដ្ឋា | បង ឬច្បង |
| អនុជ | ប្អូន |
| ឱរសា | កូនស្រី |
| ព្រះធីតុបតី | កូនប្រសាប្រុស |
| ភាគិនេយ្យ | ក្មួយប្រុស |
| នត្តា | ចៅប្រុស ឬចៅស្រី |
| រាជតន័យ | បុត្រស្តេច |
| រាជនារី | ស្រីស្នំ |
| រាជទារិកា | កូនង៉ែតស្រី |
| ........................ | .................................. |

## ខ. ពាក់ព័ន្ធនឹងសរីរាង្គកាយ

| | |
|---|---|
| មត្ថលុង្គ | ខួរក្បាល |
| យកន: ឬយក្រិត | ថ្លើម |
| លោម | រោម |
| លោមនេត្រ | រោមភ្នែក |
| វច្ចមគ្គ | ទ្វារជុះ |
| សុសោណី | ត្រគាក |
| សេម្ហ: | ស្លេស្ម |
| ហឫទ័យ | ចិត្ត ឬបេះដូង |
| ហស្ថ | ដៃ |
| អង្គុដ្ឋង្គុលី | ម្រាមដៃ |
| អង្សា | ស្មា |
| អណ្ឌ: | ពងស្វាស |
| អដ្ឋិ | ឆ្អឹង |
| អនុជង្គបាទ | ម្រាមកូនជើង |
| អន្ត: | ពោះវៀនធំ |
| អសុចិ | ទឹកកាម |
| ឧណ្ណាលោម | ប្រជុំចិញ្ចើម |

| | |
|---|---|
| មស្សុ | ពុកចង្កា ពុកមាត់ |
| រជ្ជោជល | ក្អែល |
| លោមកច្ឆ: | រោមក្លៀក |
| វង្សកុបាត | ស្លាបប្រចៀវ |
| សន្ធិករ | សន្លាក់កដៃ |
| សេទោ | ញើស |
| ស្រោត ឬសោតា | ត្រចៀក |
| ហនុតា | ចង្កា |
| តិលកា | ប្រជ្រុយ |
| អង្គុដ្ឋង្គបាទ | មេជើង |
| អង្សកូដ | ចង្កួយស្មា |
| យោនី | កេរ្តិ៍ខ្មាស់ស្ត្រី |
| អនុជង្គ | ក្រលៀន |
| អនុជង្គលី | ម្រាមកូនដៃ |
| អន្តគុណ | ពោះវៀនតូច |
| អស្សុ | ទឹកភ្នែក |
| ឧទរ | ពោះ |

| | | | |
|---|---|---|---|
| ឱរូ | ភ្លៅ | ឱរា | ដើមទ្រូង |
| ព្រះសិដ្ឋលិង្គ | កេរ្តិ៍ខ្មាស់បុរស | ព្រះសិង្ឃានិកា | សំបោរ |
| កច្ឆៈ | ក្លៀក | កដិ ឬអង្គៈ | ចង្កេះ |
| កនិដ្ឋបាទ | ម្រាមនាងជើង | កនិដ្ឋង្គុលី | ម្រាមនាងដៃ |
| កព្រះហស្ត | កដៃ | ព្រះកាយ | ខ្លួនប្រាណ |
| កាណ៌ | គុម្ពត្រចៀក | កេសា | សក់ |
| កំភួនព្រះហស្ត | កំភួនដៃ | កិរ្យ | ទឹកដោះ |
| ខេឡៈ | ទឹកមាត់ | ខេឡាសុចិ | កំហាក |
| គណ្ឌៈ | ថ្ពាល់ | គីវង្គ | កន្ទួតអូង |
| គោប្ផកៈ | ភ្នែកគោ | ឃានមលៈ | អាចម៍ច្រមុះ |
| ជង្ឃ | ស្មងជើង | ជានុ | ក្បាលជង្គង់ |
| ជីវ្ហា | អណ្តាត | តចៈឬតចោ | ស្បែក |
| ជង្ឃ | ស្មងជើង | តជ្ជនាបាទ | ចង្អុលម្រាមជើង |
| ថនា | ដោះ ឬសុដន់ | ទន្ត | ធ្មេញ |
| នខា | ក្រចក | នលាដ | ថ្ងាស |
| នហារុ | សរសៃឈាម | នាភី | ផ្ចិត |
| នាសា | ច្រមុះ | និពទ្ធបាទ ឬកព្រះបាទ | កជើង |
| បទរាជី | ក្រយៅ | បប្ផាសៈ | សួត |
| បស្សាវមគ្គ | ទ្វារនោម | បិដ្ឋិ | ឆ្អឹងខ្នង |
| បិត្តៈ | ប្រមាត់ | បិហកៈ | ក្រពះ |
| ប្រីស្តាង្គ | ខ្នង | ពាហា ឬពាហុ | កំភួនដៃ |
| ភក្ត្រ | មុខ | ភូមោ ឬភមុតា | ចិញ្ចើម |
| មជ្ឈិមង្គលី | ម្រាមដៃកណ្តាល | មជ្ឈិមបាទ | ម្រាមជើងកណ្តាល |
| លោហិត | លោហិត | វង្សកុបាទ | ស្លាបប្រចៀវ |
| ........................... | ................................ | .......................... | ................................. |

លោក **: គួយ សូគាន**

មន្ត្រីផ្នែកវិទ្យាសាស្ត្រអប់រំនៃរាជបណ្ឌិតសភាកម្ពុជា



# វិធីបង្រៀនគំនូរ (ត)

ដោយលោក : ប៉ាន់ ត្រា

## គំនូសកោង

សិស្សបានហាត់គូសគំនូសត្រង់ទាំង ៣ បែបរួចហើយ ហើយថែមទាំងបានយកគំនូសទាំងនោះមកគូសផ្សំគ្នាបានជារូបភាពផ្សេងៗ ជាផ្ទាំង និង ខ្សែតុបតែងលំអជាច្រើនទៀតផង ។

បន្ទាប់ទៅនេះ ត្រូវដឹកនាំសិស្សអោយហាត់គូសគំនូសកោងដែលជាគំនូសមានសារៈសំខាន់បំផុត ព្រោះដោយគំនូសកោងនេះ គេអាចយកទៅគូសផ្សំជារូបភាពផ្សេងៗគ្រប់បែបគ្រប់យ៉ាង ។ គេអាចគូររចនាជារបស់ប្រើប្រាស់ជាស្លឹកឈើ ផ្កាឈើ ជាសត្វ និង ជាមនុស្សនឹងគំនូសកោងនេះតែឯង ។

បើយកគំនូសកោងនេះទៅរចនាផ្សំជាមួយគំនូសត្រង់បញ្ឈរ ត្រង់ទេរទៀតនោះ គេអាចគូរជារូបភាពសព្វបែបសព្វយ៉ាងទាំងអស់ ។

គំនូសកោងមានតួនាទីសំខាន់ណាស់ ព្រោះអ្វីៗដែលមានជីវិតដូចជាសត្វ ព្រឹក្សា មនុស្ស សុទ្ធតែគូរបានជារូបរាងឡើងដោយគំនូសកោងទាំងអស់ ។

ដូច្នេះ ដើម្បីបញ្ជាក់អំពីតួនាទីដ៏សំខាន់របស់គំនូសកោងនេះ យើងជូនរូបភាពខ្លះជាឧទាហរណ៍ដូចខាងក្រោមនេះ ÷



## ការយកគំនូសកោងទៅគូររចនាជារូបភាព

កាលណាសិស្សហាត់គូសគំនូសកោងនេះបានថ្នឹកដៃគួរសមហើយ លោកគ្រូ អ្នកគ្រូត្រូវដឹកនាំសិស្សយកគំនូសកោងនោះទៅរចនាផ្សំជាមួយគំនូសត្រង់ទាំង ៣ បែបអោយកើតទៅជារូបភាពវត្ថុប្រើប្រាស់ដែលដាក់កំពស់ស្មើនឹងបន្ទាត់ខ្សែភ្នែកដូចខាងក្រោមនេះ ÷

**(ក្នុងវគ្គទី ៣ តំរូវអោយសិស្សផាត់ពណ៌)**

**វគ្គទី ១** **វគ្គទី ២** **វគ្គទី ៣**






គំនូសកោងខាងលើនេះ ក៏ដូចជាគំនូសត្រង់ទាំង ៣ បែបដែលបានហាត់គូសពីថ្នាក់ទី ១ដែរ គឺមុននឹងចាប់ហាត់គូសគំនូសថ្មីទៀត ត្រូវអោយសិស្សចេះគូសគំនូសមុនបានថ្នឹកដៃសិន ទោះបីត្រូវចំណាយពេលយូរបន្តិចក៏ដោយ ព្រោះដូចបានរាប់រៀបពីខាងដើមមកហើយថា គំនូសត្រង់ទាំង៣បែប និង គំនូសកោងនេះមានសារៈសំខាន់បំផុតក្នុងការគូររចនារូបភាពទាំងអស់ និង គូរខ្សែតុបតែងលំអគ្រប់បែបដ៏ប្រកបទៅដោយសោភ័ណភាព ។



¤ ¤ ¤ ¤ ¤ ¤ ¤ ¤

# គណិតវិទ្យា

## ការរាប់លេខ និង សរសេរលេខ និង ពាក្យ

- ថ្នាក់ទី ២
- មេរៀនទី ១
- សៀវភៅសិស្ស ទំព័រទី ២

**អត្ថបទជំនួយ:**

* **ចូរភ្ជាប់ខ្លែង និង ផ្លាក**




* **ចូរសរសេរលេខក្នុងប្រអប់ និង ហើយសរសេរពាក្យ**

☐ ដប់មួយ.......................................

☐ ដប់ពីរ.......................................

☐ ដប់បី.......................................

☐ ដប់បួន.......................................

☐ ដប់ប្រាំ.......................................

☐ ដប់ប្រាំមួយ.................................

☐ ដប់ប្រាំពីរ..................................

☐ ដប់ប្រាំបី...................................

☐ ដប់ប្រាំបួន.................................

# គណិតវិទ្យា

## វិធីគុណ និង វិធីចែក

- ថ្នាក់ទី ៤
- មេរៀនទី ៤
- សៀវភៅសិស្ស ទំព័រ ២២

**លំហាត់បន្ថែម:**

**ចំណោទទី១** : សាលាក្រុងបានផ្ដល់ប្រាក់ដល់សិស្សម្នាក់ចំនួន ៣៥០០រ ដើម្បីធ្វើដំណើរកំសាន្តទៅលេងសួនសត្វនៅពេលវិស្សមកាល ។ សាលារៀនយើងមានសិស្សចំនួន ៦៤៥ នាក់ ។ តើនាយិកាសាលាបានទទួលប្រាក់ប៉ុន្មានក្នុងឱកាសនេះ ?

**ចំលើយ** : ២ ២៥៧ ៥០០រ

**ចំណោទទី២** : នៅក្នុងខែ មិនា នេះ សីលាបានញុំាបាយ ១៣ ដង នៅអាហារដ្ឋានសាលារៀន ។ បាយមួយចានតំលៃ៥០០រ និង ទឹកអំពៅមួយកែវថ្លៃ៣០០រ ។ តើម្ដាយវាត្រូវបង់ថ្លៃអាហារអោយអាហារដ្ឋានប៉ុន្មានក្នុងខែនេះ?

**ចំលើយ** : ១០ ៤០០រ

**ចំណោទទី៣** : នៅពេលដែលកង់ខ្ញុំវិលបានមួយជុំ វាទៅមុខបាន ២.៥០ម ។ នៅពេលដែលខ្ញុំទៅដល់ផ្ទះណារ៉ាមិត្តខ្ញុំកង់របស់ខ្ញុំវិលបាន ២៦៨៥ ជុំ ។ តើខ្ញុំធ្វើដំណើរបានប៉ុន្មាន ?

**ចំលើយ** : ៦៧១២.៥០ម = ៦.៧១២៥ គ.ម

**ចំណោទទី៤** : បេះដូងរបស់យើងមានតួនាទីដូចជាស្នប់មួយ ។ ប្រសិនបើយើងយកដៃរបស់យើងដាក់លើដើមទ្រូងរឺក៏យកម្រាមដៃដាក់នៅខាងក្នុងកដៃយើងលឺសូរបេះដូងយើងដើរ ។ កុមារម្នាក់នៅស្ងៀម បេះដូងដើរជា មធ្យម ៧០ ដងក្នុង ១ នាទី ។ តើក្នុង ២៤ ម៉ោង បេះដូងរបស់វា ដើរបានប៉ុន្មានដង ?

**ចំលើយ** : ១០០ ៨០០ដង

**ចំណោទទី៥** : រោងល្ខោនមួយមាន ៤៥០ កន្លែង ។ ក្នុងមួយជួរមាន ៧ កៅអី នៅខាងស្ដាំផ្លូវ និង មាន ៨ កៅអីនៅខាងឆ្វេងផ្លូវ ។ តើរោងល្ខោននេះមានកៅអីប៉ុន្មានជួរ ?

**ចំលើយ** : ៣០ ជួរ

**ចំណោទទី៦** : យន្តហោះប្រតិកម្មមួយហោះក្នុងល្បឿន១១០០គ.មក្នុងមួយម៉ោង ដើម្បីហោះឆ្លង "ជញ្ជាំងសំលេងមួយ" ។ យន្តហោះស៊ើបការដែលហោះយឺតជាងយន្តហោះប្រតិកម្ម ៥ ដង ប៉ុន្តែល្បឿនរបស់វាក៏មិនធម្មតាដែរ ។ ចូរគណនាល្បឿនរបស់វា ?

**ចំលើយ** : ២២០ គ.មក្នុងមួយម៉ោង ។

លោកស្រី : **ឌិត សារឿត**

# គណិតវិទ្យា

## ចំនោទ

- ថ្នាក់ទី ៦

**<u>អត្ថបទជំនួយ:</u>**

* **ចូរភ្ជាប់ឃ្លាចំលើយអោយសមស្របនឹងប្រមាណវិធីនៃចំនោទខាងក្រោម ÷**

- ទឹកសមុទ្រមានចំនុះអំបិលប្រមាណ ៣៥ក្រាមក្នុងមួយលីត្រ ។ អាងងូតទឹកខ្ញុំមានបណ្តោយ ១,៨០ ម៉ែត្រ ទទឹង ០,៦០ម៉ែត្រ និង កំពស់ ០,៥០ម៉ែត្រ ប្រសិនបើខ្ញុំដាក់ទឹកសមុទ្រពេញអាង រួចខ្ញុំទុកអោយទឹកនោះរីងហួត តើអាចទទួលម៉ាសអំបិលបានប៉ុន្មាន ?

| | |
|---|---|
| ១- ក្រឡាផ្ទៃបាតអាង | a- ៥៤០ x ៣៥ = ១៨ ៩០០ ក្រ |
| ២- រ៉ូលូមអាង | b- ១,០៨ x ០,៥០ = ០,៥៤០ ម$^{៣}$ |
| ៣- ការប្តូរពី ម$^{៣}$ ទៅជាលីត | c- ០,៥៤០ m$^3$ = ៥៤០ ល |
| ៤- ម៉ាសអំបិលដែលមានក្នុងវ៉ូលូមនោះ | d- ១,៨០ x ០,៦០ = ១,០៨ ម$^{២}$ |
| ៥- ការប្តូរពីក្រាមទៅជាគីឡូក្រាម | e- ១៨ ៩០០ g = ១៨,៩ គ.ក្រ |

**<u>ចំលើយ</u>** : (១,d) (២,b) (៣,c) (៤,a) (៥,e)

- ទីក្រុងតូចមួយមានមនុស្ស ១២៧៣២ នាក់ ។ ក្នុង ១ ឆ្នាំមាន ÷
  - មនុស្សកើតចំនួន ៣២៦ នាក់ និង ស្លាប់ ១០២ នាក់
  - មនុស្ស ១២ នាក់បានផ្លាស់ប្តូរ
  - មនុស្ស ២១ថ្មីបានចូលមកនៅ
- តើនៅដំណាច់ឆ្នាំមានចំនួនមនុស្សពិតប្រាកដប៉ុន្មានរស់នៅទីនោះ ?

| | |
|---|---|
| ១- មនុស្សចេញ | a- ១០២ + ១២ = ១១៤ |
| ២- មនុស្សចំនួល | b- ១២ ៧៣២ + ២៣៣ = ១២ ៩៦៥ |
| ៣- កំហុសគ្នារវាងអ្នកចូល និង អ្នកចេញ | c- ៣២៦ + ២១ = ៣៤៧ |
| ៤- ចំនួនមនុស្សរស់នៅសរុប | d- ៣៤៧ - ១១៤ = ២៣៣ |

**<u>ចំលើយ</u>** : (១,a) (២,c) (៣,d) (៤,b)

លោកស្រី : **កែវ សុបុរិន្ទ**
សាស្ត្រាចារ្យនៅមហាវិទ្យាល័យគរុកោសល្យ

★☆★☆★☆★

# សិក្សាសង្គម

## សុជីវធម៌

- ថ្នាក់ទី ៦
- មេរៀនទី ១ : សុជីវធម៌
- សៀវភៅសិស្សទំព័រទី ១-៣

**អត្ថបទជំនួយ:**

**សុជីវធម៌ប្រចាំថ្ងៃ ៣ យ៉ាង** (ការរស់នៅល្អប្រកបដោយធម៌)

១. ត្រូវចេះ សរសើរ

២. ត្រូវចេះ អរគុណ

៣. ត្រូវចេះ សុំអភ័យទោស

* **សរសើរ** : គឺជាសំដីនិយាយ ឬលិខិតដែលឆ្លើយតបវិញយ៉ាងសមរម្យ និង អំពើល្អរបស់បុគ្គលពួកក្រុមណាមួយ ។

នៅក្នុងគ្រួសារ បើកូនបានធ្វើល្អដោយកាយក្តី វាចាក្តី អ្នកជាមាតាបិតាត្រូវចេះពោលសរសើរផ្តល់កំលាំងចិត្ត។ កូនរៀនពូកែបានពិន្ទុល្អ ម្តាយឪពុកត្រូវចេះសរសើរកូនអោយកំលាំងចិត្តដូចជានិយាយថា : កូនម៉ែរៀនបានចំនាត់ថ្នាក់ល្អ នេះបានជាកូនម៉ែ កូនរៀនពូកែដូចពុកម៉ែអញ្ចឹង ! ចាំពុកម៉ែទិញខោអាវស្បែកជើងថ្មីៗអោយ !

កូនឮដូច្នោះ វាត្រេកអររំភើបខ្លាំងណាស់ ។ ប៉ុន្តែរឿងទិញខោអាវ ស្បែកជើង បើវារៀនមិនពូកែមិនដែលឪពុកម្តាយណាមួយអោយកូនអត់នោះទេ ។ ឧទាហរណ៍ប៉ុណ្ណេះហៅថា "ចេះសរសើរ" ចេះអោយកំលាំងចិត្ត ។ ឪពុកម្តាយខ្លះ កូនទៅរៀន គ្រូបានដាក់ពិន្ទុអោយ :១០/១០ល្អណាស់! កូនអរណាស់ មកដល់ផ្ទះមិនទាន់ទេ និយាយប្រាប់ឪពុកម្តាយថា : ខ្ញុំបានពិន្ទុ ១០! ស្រាប់តែឪពុកម្តាយឆ្លើយវិញថា : អាអែង ស៊ីដប់ហ្នឹងទៅ ! កុំស៊ីបាយ ! អញរវល់មួយព្រឹកអត់អ្នកណាជួយអញ ! គោអត់អ្នកណាឃ្វាល ! អាអែងមើលកូនគេផ្ទះខាងជើង គេបាចត្រីបានមួយទ្រុង មួយកញ្ច្រែង ។ កូនឮដូច្នេះបាត់ព្រលឹងរៀនសូត្រអស់រលីង ! ។

ស្វាមីភរិយា ត្រូវចេះពោលសរសើរគ្នាទៅវិញទៅមក ។ ដូចជានិយាយថា ថ្ងៃនេះម៉ាក់វា ឬម៉ែវា... ធ្វើម្ហូបឆ្ងាញ់ណាស់! រៀបចំផ្ទះក៏បានល្អ! ម៉ាក់វាថ្ងៃនេះហត់នឿយខ្លាំងណាស់។ សូមជ្រាបថា : មនុស្សស្រីឆាប់ទទួលសេចក្តីរំភើបរីករាយណាស់ ។ ចំពោះមនុស្សប្រុសជាស្វាមីវិញ ស្ត្រីជាភរិយាត្រូវចេះពោលសរសើរ ចេះអោយកំលាំងចិត្ត ។ សូមជ្រាបថា : សំដីនារី សំលេងនារី មានឥទ្ធិពលខ្លាំងណាស់ទៅលើបុរស ពិសេសបុរសជាស្វាមី ។

"នារីល្ងង់បំផុតម្នាក់ ក៏អាចដឹកច្រមុះបុរសវៃឆ្លាតបានដែរ ។ ប៉ុន្តែទាល់តែនារីប៉ិនប្រសប់ណាស់ ទើបអាចដឹកនាំបុរសល្ងង់ខ្លៅបាន" ។

នៅក្នុងសង្គមក៏ត្រូវចេះពោលសរសើរដែរ ឃើញកុមារ យុវជន ចេះគួរសម ជំរាបសួរ... យើងត្រូវនិយាយសរសើរកូនចៅ លោក អ្នកណាចេះគួរសមល្អណាស់ ! ឃើញភូមិស្រុក វត្តអារាម សាលារៀន រៀបចំបានល្អត្រឹមត្រូវមានសណ្តាប់ធ្នាប់ក៏ត្រូវចេះពោលសរសើរ ។

នៅក្នុងសង្គមជាតិទាំងមូលក៏ដូច្នោះដែរ អ្នកដឹកនាំណាធ្វើការបំរើជាតិបានល្អ មានការអភិវឌ្ឍន៍គ្រប់វិស័យស្គាល់សុខទុក្ខប្រជាជន... យើងត្រូវចេះពោលសរសើរលើកតំកើងគាំទ្រ ទោះបីអ្នកនោះមាននិន្នាការនយោបាយសាសនាខុសគ្នាក៏ដោយ យើងត្រូវផ្តល់យុត្តិធម៌ជូន នេះជាច្បាប់សុជីវធម៌ ។ ផ្ទុយទៅវិញ ជនពួកខ្លះគេធ្វើល្អសំរាប់ជាតិ សំរាប់ប្រជាជនបានច្រើនណាស់ អត់ដែលឮសូរពាក្យគាំទ្រ ពោលសរសើរតែមួយម៉ាត់គ្មាន ។ ជនប្រភេទនេះទោះបីរៀនសូត្របានច្រើនមានសញ្ញាប័ត្រខ្ពស់ដល់ណាក៏ដោយ "ច្បាប់សុជីវធម៌"អោយឈ្មោះថា ជាមនុស្សល្ងង់ផុតលេខ ។ ចំពោះផ្លូវចិត្តវិញ ជនប្រភេទនេះគ្មានសេចក្តីសុខទេ មានសេចក្តីក្តៅក្រហាយច្រណែនឈ្នានីសជានិច្ច ។

សូមជ្រាបថា : វន្ទកោ បដិវន្ទនំ បើសំពះគេ ត្រូវបានគេសំពះតបវិញ, បូជកោ បដិបូជនំ បើបូជាគេត្រូវគេបូជាតបវិញ ។ "សំពះគេ គឺសំពះខ្លួនឯង, បូជាគេ គឺបូជាខ្លួនឯង" ។

***អរគុណ**: គឺជាអំពើឆ្លើយតបវិញចំពោះបុគ្គល ពួក ក្រុមណាមួយដែលបានធ្វើល្អចំពោះខ្លួន ឬក្រុមគ្រួសារខ្លួន ។

ដឹងគុណ និង អរគុណ មានន័យដូចគ្នានឹងពាក្យថា : កតញ្ញូ : ដឹងគុណ, កតវេទី : តបគុណ ។ គេធ្វើអំពើល្អមកលើខ្លួន ហើយមិនបានឆ្លើយតបវិញ តាមន័យពុទ្ធសាសនាថា "ជនអកតញ្ញូ" ធ្ងន់ធ្ងរជាងនេះទៅទៀត គឺប្រឆាំងនឹងអ្នកមានគុណ ហើយមើលងាយអ្នកមានគុណ ។ បើបោះបង់ចោលធម៌កតញ្ញូកតវេទីហើយ ពុទ្ធសាសនាស្ទើរតែគ្មានន័យទាល់តែសោះ ។ ព្រះសម្ពុទ្ធទ្រង់សំដែងថា : កតញ្ញូតាធម្មមូលា ការដឹងគុណជាឫសគល់នៃកុសលធម៌ទាំងពួង កតញ្ញូតាបធានតាការដឹងគុណជាប្រធាននៃកុសលធម៌ទាំងពួង ។

សុភមង្គលរបស់មនុស្សស្ថិតនៅត្រង់ស្គាល់គុណគ្នា និង ចេះសងគុណគ្នាទៅវិញទៅមក( ចេះអរគុណគ្នាទៅវិញទៅមក) ។

ជនមិនចេះអរគុណ គឺជនបំភ្លេចគុណ មូលបង្កាច់អំពើល្អរបស់អ្នកដទៃ បើមិនចេះអរគុណគ្នា សង្គមពោរពេញអំពើអាក្រក់ ព្រោះតែខ្វះអរគុណ ។

"ជនណាមិនដែលធ្លាប់ធ្វើអ្វីខុស គឺជននោះមិនធ្លាប់ធ្វើអ្វីឡើយ" ។ "ចាំតែសំលឹងមើលកំហុសអ្នកដទៃ ជាសញ្ញាថាភ្លេចមើល កំហុសខ្លួនឯង" ។

***សុំអត់ទោស**: រាល់អំពើរបស់បុគ្គលម្នាក់ៗដោយកាយក្តី ដោយវាចា ពាក្យសំដីក្តី អាចនឹងមានការភាន់ច្រឡំខុសឆ្គងខ្លះៗទៅលើអ្នកដទៃ ទោះបីជាចេតនាក្តី អចេតនាក្តី ចៀសមិនផុតឡើយ វាជាការធម្មតារបស់មនុស្សលោកយើង ប៉ុន្តែប្រការដែលសំខាន់ គឺហ៊ានទទួលខុសត្រូវកំហុសរបស់ខ្លួន សំខាន់ជាងនេះទៀត

គឺចេះសុំអភ័យទោស ។ អ្នកស្គាល់កំហុសរបស់ខ្លួន គឺជាអ្នកប្រាជ្ញ ។ ប៉ុន្តែមនុស្សពោលពិបាកនឹងលើកដៃសុំទោសគេណាស់ ! តែបើលើកដៃវាយគេវិញ អាចធ្វើបាន ។

លោកអ្នកប្រាជ្ញពីបរមបុរាណបានពោលថា : ការបរិភោគអាហារ ១, ការដេក ១, សេចក្ដីភ័យខ្លាច ១, និងសេពមេថុន ១ ទាំង៤ប្រការនេះមនុស្ស និង សត្វមានស្មើគ្នា(ដូចគ្នា) មានតែសុជីវធម៌ប៉ុណ្ណោះទេ ទើបអាចធ្វើមនុស្ស និង សត្វអោយវិសេសប្លែកពីគ្នា អ្នកណាប្រាសចាកសុជីវធម៌ អ្នកនោះទុកស្មើសត្វ ។

លោក : **អ៊ុយ សុន**

នាយកសាលាបឋមសិក្សាព្រែកកំពឹស

✠✠✠✠✠✠✠

**គុណធម៌ប្រាំបីយ៉ាង សំរាប់បុគ្គលសក្តិសមនឹងបំពេញបេសកកម្មមួយបាន បុគ្គលនោះជា÷**

- **អ្នកចេះ**
  - ស្ដាប់គេ
  - ធ្វើអោយអ្នកដទៃស្ដាប់ខ្លួន
  - រៀន
  - ចងចាំ
  - ទទួលស្គាល់គេ
  - ធ្វើអោយអ្នកដទៃទទួលស្គាល់ខ្លួន
- **អ្នកស្ទាត់ជំនាញដើម្បីស្គាល់**
  - អ្នកមានវិរិយភាពម៉ឺងម៉ាត់
  - អ្នកគ្មានវិរិយភាពម៉ឺងម៉ាត
- **អ្នកមិនមែនជាអ្នកបង្កអោយមានការច្របូកច្របល់** ។

**កម្ពុជសុរិយា**




# កំណាព្យសុភាសិត

(បទពាក្យ៧)

១- **ឥត** បុត្រទៅសុំឯកូនគេ
២- **ដំណោះ**ផ្ទុករេធ្វើជាកូន
៣- **ចៅ**ដោះមនុស្សឈ្មួលជួលបងប្អូន
៤- **ចៅ**អស់តាដូនមកចងដៃ ។
៥- **ជំទី**ឈឺខ្លួនកូនមិនឈ្ងោក
៦- **ដំណាំ**ថែមរោគជោគរាល់ថ្ងៃ
៧- **ចោង**ដោះគេប្រែនិស្ស័យ
៨- **មិន**ថ្ងៃច្នេះច្នោះព្រោះក្រៅសាច់ ។
៩- **ឈើ**ជាតែឯងកូនមិនសួរ
១០- **យក**គួរតែនិងពោងសំបាច់
១១- **ឈើ**កោងវល្លិព័ទ្ធមនុស្សព្រាត់ដាច់
១២- **ចាក់**ចោលទៅស្រេចកាច់ទៅជា ។

* តាមរយៈកំនាព្យនេះ អ្នកនិពន្ធបានលើកភាសិតខ្មែរពីរ ។ ប្រសិនបើអ្នកចង់ស្គាល់ភាសិតនោះ សូមអ្នកភ្ជាប់ព្យាង្គទី ១ នៃឃ្លារបស់កំនាព្យលើកលែងតែក្នុងឃ្លាទី ៥ ត្រូវយកព្យាង្គទី ១ និង ទី ២ ។

ដកស្រង់ដោយ : **ឈោក ថេង**
គ្រូបង្រៀន វិទ្យាល័យដំដែក
ស្រុកសូទ្រនិគម ខេត្តសៀមរាប

**ជនដែលមិនធ្លាប់ធ្វើអ្វីខុសសោះ ក៏គឺជនដែលមិនធ្លាប់ធ្វើអ្វីឡើយ ៕**

ណាប៉ូឡេអុង

# ស្មារតីគ្រូបង្រៀន

១- ក្នុងនាមជាគ្រូ មានភាពគំរូ ដល់សិស្សប្រុសស្រី ខិតខំបង្រៀន
ស្រាវជ្រាវរាល់ថ្ងៃ បណ្តុះស្មារតី ចិត្តសាស្ត្រកុមារ ។

២- លោកគ្រូអ្នកគ្រូ មានចិត្តតស៊ូ ស្វែងយល់ខ្លឹមសារ លំហាត់មេរៀន
ដោះស្រាយបញ្ហា ដើម្បីសាលា និងសិស្សទាំងអស់ ។

៣- មិនថាព្រឹកថ្ងៃ គេងគិតរំពៃ ស្មារតីស្ម័គ្រស្មោះ អប់រំទូន្មាន
ទាំងស្រីទាំងប្រុស អោយមានកិត្តិយស ខ្ពង់ខ្ពស់ថ្លៃថ្លា ។

៤- រាល់ថ្ងៃសំភី កិច្ចការវក់វី ធ្វើកិច្ចតែងការ យកទៅបង្រៀន
នៅក្នុងសាលា បណ្តុះកុមារ ក្លាយជាសិស្សល្អ ។

៥- រាល់ថ្ងៃព្រឹកល្ងាច តែងខិតខំឆ្លៀត ធ្វើឧបករណ៍ ធនធានផ្សេងៗ
ដូចជាអក្សរ រូបភាពល្អៗ សំរាប់បង្រៀន ។

៦- មកដល់ក្នុងថ្នាក់ ញញឹមរាក់ទាក់ ភ្នែកមើលក្តារខៀន ដៃជាប់ដីស
សួរសិស្សប្រធាន ពិនិត្យវត្តមាន ប្រចាំថ្ងៃថ្មី ។

៧- ចំពោះសិស្សប្រុស អង្គុយចំរុះ ជាមួយសិស្សស្រី ដាក់ដៃលើតុ
ចាំស្តាប់សំដី តើគ្រូសួរអ្វី នៅក្នុងថ្នាក់រៀន ។

៨- បន្ទាប់ទៀតមក គ្រូខំរិះរក ផ្លាស់ប្តូរល្បិចល្បៀន ដើម្បីចាប់ចូល
ខ្លឹមសារមេរៀន ងាយស្រួលបង្រៀន នូវមេរៀនថ្មី ។

៩- បន្តបន្ទាប់ គ្រូត្រូវទំលាប់ ប្រើបច្ចេកល្បី បច្ចេកទីមួយ
ទីពីរទីបី និងទីបួនថ្លៃ ត្រូវយល់អោយច្បាស់ ។

១០- ពេលម៉ោងចេញលេង សិស្សប្រុសស្រីក្មេង មិនលេងផ្តេសផ្តាស់ ចំនែកគ្រូវិញ
ភ្នែកគន់របស់ ក្រែងមានពារប៉ះ ដល់សិស្សគ្រប់គ្នា ។

១១- ឱគ្រូបឋម មនសិការជាតិធំ បំរើការងារ បុគ្គលិកម្នាក់ៗ
ខិតខំពុះពារ កសាងកម្ពុជា អោយបានក្តីសុខ ។

ដោយលោក : **មិន រឹម**
សាលាសាមគ្គីបឹងស្នាច់ ខេត្តព្រៃវែង

# អក្សរចំណោទ

ដូនតាយើង លោកឧស្សាហ៍រកល្បែងដែលនាំអោយបែកគំនិតប្រាជ្ញាមានអក្សរចំនោទជាដើម តែបើយកអក្សរចំនោទជំនាន់មុនមកចោទសួរក្មេងសម័យនេះ ឃើញថាពិបាកគិត អានអោយបានត្រឹមត្រូវណាស់ដោយជំនាន់មុនស្រះអា ហៅថា ទាញយារ, ស្រះអុ ហៅថា រុកជើង, ស្រះអេ ហៅថាបាំងឈើ, ស្រះអំ ហៅដំលើ, ស្រះអះ ហៅថារះមុខ ។

ដូចនេះ បើយកអក្សរចំនោទជាន់មុនមកចោទ ត្រូវលោកអ្នកនាងគិតតាមឈ្មោះស្រះដែលគេហៅជាន់មុនទើបអានបានសេចក្ដីល្អ ។ ឯការអានអក្សរចំនោទត្រូវអានអោយបានជាពាក្យល្អតាមភាពចំនោទ : ឧទាហរណ៍ ដូក៌ . "ដូកដំបី" ។

ដកស្រង់ដោយ : **កែវ យ៉ារ**

(ប្រភព : ខេមរយានកម្ម លេខ ១ វិច្ឆិកា ១៩៦៧)

***កំនត់សំគាល់:** អ្នកគ្រូ លោកគ្រូអាចណែនាំសិស្សស្រាវជ្រាវដាក់ចំនោទដោយខ្លួនឯង មិនបាច់រកពាក្យដែលមានហើយនោះទេ ។ ឧទាហរណ៍ : ក្បាលត្រូវដំលើបីដងអាច :

គូរក្បាលដាក់ស្រះដំលើ៣ ៌ រឺ ° ចំនួន៣ដាក់លើពាក្យក្បាល >ក្បា៌ល

បាំងឈើបន្ទប់ : េ = បាំងឈើ + បន្ទប់ > បេន្ទប់ = បាំងឈើបន្ទប់

នៅពេលត្រិះរិះពិចារណា ព្រះពុទ្ធអង្គច្រើនសំដែងកាយវិការ ( មុទ្ទ=មុទ្រ) ព្រះហស្ដច្រើនយ៉ាងដូចជា :



ធម្មចក្កមុទ្រ

( កាយវិការកំពុងធ្វើអត្ថាធិប្បាយ)



ឈានមុទ្រ

( កាយវិការសមាធិ)



អភ័យមុទ្រ

( កាយវិការអប់រំកុំឱ្យភ័យ ខ្លាចអ្វី១ដែលពុំទាន់ពិចារណា)



វរមុទ្រ

(កាយវិការអប់រំឱ្យមានចិត្តសប្បុរស)



វិតកមុទ្រ

( កាយវិការកំពុងពិចារណារកខុសត្រូវ)



ភូមិស្សសមុទ្រ

( កាយវិការយកព្រះធរណីជាសាក្សី)

* តើអ្នកចូលចិត្តប្រើកាយវិការដូចម្ដេចខ្លះ នៅពេលអ្នកគិតអ្វីមួយ ?

# ភ្នំព្រះធាតុ

ប្រសិនបើយើងធ្វើដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ ៥ រួចបត់ឆ្វេងត្រង់ផ្សារត្រាច តាមផ្លូវលំចាក់គ្រួសក្រហមមួយខ្សែយ៉ាងរាបស្មើរហូតដល់ខ្លោងទ្វារ "ច្រកស្តេច" រួចធ្វើដំណើរលើផ្លូវដែលមិនទាន់អភិវឌ្ឍមួយខ្សែទៀតមានចំងាយ ១៧គ.ម. យើងនឹងដល់ជើងភ្នំមួយ នោះគឺភ្នំព្រះធាតុ ។



ភ្នំព្រះធាតុ គឺជាភ្នំមួយដែលអ្នកស្រុកនៅតំបន់នោះហៅតៗគ្នាមក ដោយមានការចងចាំថាពាក្យនេះត្រូវតែហៅដោយសង្ខេបនូវឈ្មោះពេញលេញមួយថា "ភ្នំព្រះសិរីរិកធាតុ" ។ លោកតា លោកយាយចាស់ស្រុកនៅទីនោះបានអោយដឹងថា "ពីដើមយូរលង់មកហើយ មានព្រះសង្ឃធុតង្គ២អង្គជាបងប្អូនបង្កើតនឹងគ្នា បានធ្វើតបះធម៌នៅទីនោះ ប្រាថ្នានឹងសំរេចអរហត្តផល ។ ក្រោយពីចំរើនភាវនាអស់ជាច្រើនវស្សា ក៏មានគំនិតចង់អធិដ្ឋានមើលកុសលបារមីថា ក្នុងចំណោមពួកគាត់ទាំង២អង្គ តើមួយណានឹងបានសំរេចធម៌មុនគេ ? ទើបនាំគ្នាអធិដ្ឋានដាំឈើច្រត់រៀងៗខ្លួន ថាបើឈើច្រត់អ្នកណាមានដុះស្លឹក និង ផ្កាមុនគេ ម្ចាស់ឈើច្រត់នោះនឹងបានសំរេចធម៌មុនគេដែរ ។ ក្រោយមកឈើច្រត់របស់ព្រះសង្ឃច្បងបានដុះចេញផ្កាមុន សង្ឃប្អូនឃើញដូច្នោះក៏កើតគំនិតច្រណែន រួចលួចដកឈើច្រត់ដុះផ្កានោះទៅដូរនឹងឈើច្រត់គ្មានផ្ការបស់ខ្លួន ។ ដោយអំណាចនៃញាណសង្ឃច្បងបានដឹងរឿងទាំងអស់ ប៉ុន្តែមិនមាត់ក ឬស្តីបន្ទោសអ្វីឡើយ ព្រោះខ្លួនជាអ្នកកាន់សីល ។ ដោយសេចក្តីមិនស្មោះត្រង់បែបនេះ អព្ភូតហេតុបានកើតឡើយ ។ ថ្មកំពូលភ្នំមួយដុំធំ បានប្រេះបែកជាពីរដុំ មួយនៅឈរវាងជាលិង្គធម្មជាតិ ដូចយើងឃើញនាពេលសព្វថ្ងៃ និងមួយដុំធំទៀតបែកធ្លាក់ទៅជំរាលជាប់ពីខាងនិរតីនៃទម្រថ្មលិង្គធម្មជាតិនោះឯង ។ ក្រោយពីព្រះសង្ឃច្បងអង្គនោះអនិច្ចធម្មទៅ អ្នកស្រុកបានយកព្រះធាតុរបស់គាត់ទៅបញ្ចុះលើថ្មដុលមួយដុំធំរាងដូចគុកស្តុរឡោតយក្ស ១ នៅមុខប្រាសាទថ្មបាយក្រៀមផ្នែកខាងស្តាំដៃ ។ ដោយសារផ្អែកលើរឿងនេះហើយ ទើបអ្នកស្រុកហៅឈ្មោះភ្នំនោះថា "ភ្នំព្រះសិរីរិកធាតុ" តែការហៅនេះបានរួញខ្លីមសារនៅត្រឹម "ភ្នំព្រះធាតុ" វិញ ។

ភ្នំនេះស្ថិតនៅមិនឆ្ងាយប៉ុន្មានពីក្រុងឧត្តុង្គអតីតរាជធានីខ្មែរ ហើយដែលតឡូវនេះស្ថិតនៅក្រោមការគ្រប់គ្រងនៃឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ ទីនេះគឺជាជាយព្រៃអមលាំង យើងអាចធ្វើដំណើរដោយរទេះគោអស់រយៈពេលមួយព្រឹកទើបទៅដល់ទ្រូងព្រៃនេះ ។ ឈើប្រណីតៗមានតំលៃដូចជា សុក្រំ ធ្នឹក នាងនួន កកោះធំៗខ្ពស់ៗ នៅក្នុងដងព្រៃដែលព័ទ្ធជុំវិញភ្នំព្រះធាតុបានចោលម្លប់ត្រឈឹងត្រឈៃធ្វើអោយទីនេះ ទទួលខ្យល់អាកាសល្អបរិសុទ្ធគ្រប់រដូវកាល បង្កើតនូវអារម្មណ៍រីករាយមនោរម្យដល់ពួកទេសចរដែលបានទៅដល់ ។



នៅក្នុងព្រៃក្បែរភ្នំនេះ គេបានប្រទះឃើញរុក្ខជាតិព្រៃភ្នំប្លែកៗជាច្រើនដូចជា រុក្ខជាតិកំរម្យ៉ាងដែលអ្នកស្រុកហៅថា "ដើមចាក់ក្រឡេក" ។ ការអោយឈ្មោះដូចនេះ ព្រោះយោងទៅតាមសភាពធម្មជាតិនៃរុក្ខជាតិនេះដែលកាលណាមានមនុស្ស ឬសត្វណាមួយទៅប៉ះដើមនេះ សូម្បីតែបន្តិចក៏រុក្ខជាតិនេះញ័ររញ្ជួយតាំងពីគល់រហូតដល់ចុងមានអាការៈដូចមនុស្សសើច ពេលណាត្រូវគេចាក់ក្រឡេកយ៉ាងនេះដែរ ។ ក្រៅពីនេះទៀត នៅតាមជើង និង ចង្កេះភ្នំយើងឃើញមានផ្ទាំងថ្មធំៗខ្ពស់ៗច្រូងច្រាងជាច្រើនដុំទ្រេតទេរទៅរកគ្នា បង្កើតបានជាប្រលោះធំៗ ហើយទេសចរទាំងឡាយដែលបានទៅដល់ទីនោះ តែងតែយករូងទាំងនោះធ្វើជាកន្លែងបរិភោគអាហារ និង ទទួលទានដំណេកស្រួបយកអាកាសធាតុត្រជាក់ និង បរិសុទ្ធ ។ នៅតាមជើងភ្នំ ផ្ទាំងថ្មដែលមានផ្ទៃរាបស្មើ និង ផ្ទៃក្រឡាធំៗ គឺជាកន្លែងដែលល្អប្រសើរសំរាប់ការបោះតង់ (Camping) ។

និយាយរួម ភ្នំព្រះធាតុ គឺជាឋានសួគ៌សំរាប់ទេសចរ និង ជាទឹកដីដែលមានសក្តានុពលសំរាប់ទេសចរណ៍គ្រប់ផ្នែកដូចជា វប្បធម៌ ប្រវត្តិសាស្ត្រ និង ទេសចរណ៍ធម្មជាតិ ។ អ្នកស្រុកនៅជិតខាងតំបន់នេះដូចជាពួកអ្នកផ្សារត្រាច ឧត្តុង្គ លង្វែក សាលាលេខ៥ តែងតែធ្វើដំណើរទៅបន់ស្រន់សុំសេចក្តីសុខព្រមទាំងទៅកំសាន្តកាយជាពិសេសពេលមានពិធីបុណ្យប្រពៃណីជាតិសំខាន់ៗដូចជា បុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំជាដើម ។

សូមបញ្ជាក់ថា វត្ថុដ៏មានតំលៃដែលគួរអោយចាប់អារម្មណ៍នៅភ្នំព្រះធាតុ គឺលិង្គធម្មជាតិដ៏ធំកំរបានជួប, ប្រាសាទបុរាណ, បារាយណ៍ទឹកពីបុរាណ ព្រៃឈើ និង ផ្ទាំងថ្មធម្មជាតិដ៏ចំលែកបែបស្លាបក្អែងសំពៅ ។

ដូចនេះភ្នំព្រះធាតុ គឺជាទីតាំងប្រវត្តិសាស្ត្រមួយដ៏សំខាន់ ទទួលឥទ្ធិពលព្រាហ្មសាសនាដែលបង្ហាញជំនឿទំនៀមទំលាប់ ប្រពៃណីរបស់ប្រជាពលរដ្ឋខ្មែរពីអតីតកាល(សម័យអង្គរ) ហើយក៏ជាទីតាំងរមណីយដ្ឋានសំរាប់ភ្ញៀវទេសចរជាតិ និង អន្តរជាតិនាពេលអនាគតផងដែរ ។

ដកស្រង់ដោយ : **កែវ យ៉ារ**

(ប្រភព : ទស្សនាវដ្តីសង្គមសាស្ត្រ-មនុស្សសាស្ត្រ ឆ្នាំទី ៣៣ លេខ ៤២)



# សណ្ឋាននៃកិរិយាសព្ទ

អក្សរជាគូនឹងគ្នាក្នុងវគ្គ ពាក្យយាវចេញពីពាក្យដើម រឺបែកចេញពីពាក្យដើមហៅថា កិតៈ រឺក្រិត ។ ផៅនៃពាក្យទាំងឡាយសឹងបែកចេញទៅពី ÷

- តួឯង ឧទាហរណ៍ : កើត > កំណើត, ចង់ > ចំណង់... ។
- អក្សរជាគូ ឧទាហរណ៍ : កោស > ខ្មោស, គាប > ឃ្នាប, បួស > ផ្នួស... ។

កិរិយាដែលបែកទៅជានាមហៅថា កិរិយាក្រិត ។ នាមដែលចេញពីកិរិយាហៅថា នាមក្រិត រឺហៅថាកិតនាមក៏បាន ។ កិតនាមខ្លះជាកិរិយាដាក់ជានាម ហាក់ដូចជាប្រយោគដោយប្រើអ្នក ការ សេចក្ដី ខាងដើមកិរិយា ឧទាហរណ៍ : អ្នកដើរ អ្នករែក អ្នកដេក អ្នកមក អ្នកចេះ ... ។

ចំណែកន័យពាក្យដែលជាផៅនឹងគ្នា ច្រើនសំដែងឡើងជា ÷

- អំពើ : កោស
- សកម្មភាព : ការកោស ( កំណោស)
- ឧបករណ៍បំរើការងារ : ខ្មោស
- អ្នកបំពេញការងារ : អ្នកកោស( ខ្មោស)
- វត្ថុសំរេចបានពីការងារ : កំណោស...

..........................................................................

សព្វថ្ងៃនេះ គេមិននិយមអនុវត្តវេយ្យាករណ៍បានទូលាយទេ គេប្រទះឃើញពាក្យបូរាណប៉ុន្មានគេអនុវត្តប៉ុណ្ណោះ ឧទាហរណ៍សំរាប់ប្រើក្នុងពាក្យសំដែងពីអ្នកបំពេញការងារ : ចាំ > ឆ្មាំ ( អ្នកចាំ), ដើរ > ថ្មើរ, សូម > ស្នូម, ជួញ > ឈ្នួញ ... ។ ក្រៅពីនេះ គេនិយមយក "អ្នក" មកប្រើពាក្យដាក់ពីមុខកិរិយា ឧទាហរណ៍ : អ្នកកោស មិនមែន "ខ្មោស", អ្នកគាប មិនមែន "ឃ្នាប", អ្នកកាត់ មិនមែន "ខ្នាត់" ... ។

ម្យ៉ាងទៀត ពាក្យខ្លះហាក់បីដូចប្រើជាអ្នកធ្វើសកម្មភាពទៅជាឧបករណ៍សំរាប់ធ្វើសកម្មភាពវិញ ឧទាហរណ៍ : ឃោះ > ឃ្នោះ បើយោលទៅតាមឧទាហរណ៍ខាងលើ ហើយប្រសិនបើពាក្យ "ឃ្នោះ" មិនមែនជាពាក្យ

កើតឡើងដោយអក្សរផ្ញើជើងនោះ មិនមែនជាសន្ទានកិរិយាស័ព្ទ "គោះ" ។

ដូចនេះ ដើម្បីងាយស្រួលក្នុងការរៀនសូត្ររបស់ពលរដ្ឋយើងក៏ដូចជាជនបរទេសដែលគេចង់រៀនភាសាយើង គួរមានអនុវត្តន៍មួយទូទៅ ។ ជាក់ស្ដែងតារាងខាងក្រោមនេះ គ្រាន់តែជាក្បួនប៉ុណ្ណោះ ÷

| អំពើ | សកម្មភាព | ឧបករណ៍ប្រើប្រាស់ | អ្នកធ្វើសកម្មភាព | វត្ថុសំរេចបាន |
|---|---|---|---|---|
| កាត់ | កំនាត់ | ខ្នាត់ | ខ្នាត់ | កំណាត់ |
| កោស | កំនោស | ខ្នោស | ខ្នោស | កំណោស |
| ក្បៀរ | កំនៀរ | ខ្នៀរ | ខ្នៀរ | កំនៀរ |
| គាប | គំនាប | ឃ្នាប | ឃ្នាប | គំនាប |
| ចាត់ | ចំនាត់ | ឆ្នាត់ | ឆ្នាត់ | ចំណាត់ |
| ថៃ | តំហែ | ត្នៃ | ត្នៃ | តំហែ |
| ជាន់ | ជំនាន់ | ឈ្នាន់ | ឈ្នាន់ | ជំនាន់ |
| ........................ | ........................ | ........................ | ........................ | ........................ |

លោក : ម៉ុម សុម៉ាច
បណ្ណារក្សនៅមហាវិទ្យាល័យគរុកោសល្យ

**ជនណាមាន÷**

- **អោជនគ្រាន់តែញ៉ាំងអោយប្រព្រឹត្តទៅ**
- **មេថុនគ្រាន់តែបន្តពូជ**
- **វាចាសំរាប់តែពោលពាក្យសម្ជះ**

**ជននោះ ឈ្មោះកន្លងផុតនូវឧបសគ្គដ៏លំបាកបានហើយ ។**

ស្រីហិតោបទេសភាគទី ៤

# អំនានខុសពីសំនេរ

## I. អំនានពាក្យខ្មែរដែលយកពីពាក្យបាលីសំស្ក្រឹតមកប្រើ

ចំពោះព្យញ្ជនៈ អឃោសៈ (ពួក អ) កាលណាផ្សំជាមួយស្រៈ "េ" (អេ) ត្រូវអានជាសំលេងស្រៈ "ែ" (អែ) ។ អំនានបែបនេះ គឺជាទំលាប់របស់បុព្វបុរសយើងតាំងពីយូរមកហើយ ។ រីឯវចនានុក្រមខ្មែរយើង ក៏បានណែនាំអោយអានចេញជាសំលេងស្រៈ "ែ" នូវពាក្យមួយចំនួនដែរ ។ នៅក្នុងសៀវភៅកំនាព្យខ្មែរភាគ១ បោះពុម្ពឆ្នាំ ១៩៨៤ របស់ក្រសួងអប់រំបានធ្វើកំនត់សំគាល់ថា :

ចំពោះពាក្យក្លាយពីបាលី សំស្ក្រឹត ដែលសរសេរជាមួយតួអេ (េ-) មានសូរជាអែ (ែ-) ក្នុងករណីប្រកបនឹង ត, ធ, ព, ល ។

*ឧទាហរណ៍:*

- ហេតុ អានថា ហែត
- ខេត្ត អានថា ខែត
- ចេត្រ អានថា ចែត
- អចេលក៏ អានថា អចែល
- បដិសេធន៏ អានថា បដិសែត
- ..............................................

ប៉ុន្តែតាមកំនត់សំគាល់របស់ខ្ញុំដែលមាននៅក្នុងវចនានុក្រមខ្មែរ ឃើញមានច្រើនជាងកំនត់សំគាល់ក្នុងសៀវភៅកំនាព្យខ្មែរ ។

ខ្ញុំសូមដកស្រង់យកពាក្យទាំងនោះមួយចំនួនមកបង្ហាញជូន :

កេសរ (អានថា : កែ ស) ន. (សំ.បា) លំអងផ្កា កេសរផ្កា ។ សំនុំរោមវែង១ត្រង់កសត្វចតុប្បាទ មានសីហជាដើម ។

កេណ្ឌ (អានថា : កែន) កិ. បង្គាប់, កំនត់, សំគាល់, ទាយកំនត់ទុក ។

ចេស្តា (អានថា : ចែស ស្តា) ន. (សំ) សេចក្តីខ្មីឃ្មាត, សង្វាត, ប្រឹងប្រែង, ដំនើរតាំងចិត្តប្រុងនឹងធ្វើដំនើរកំរើកអវយវៈតូចធំ មានលើកដៃជើង រឺងាកបែរជាដើម ។ ការសំដែងឫកពារអោយឃើញតេជៈអំនាច, ការប្រើអំនាច, បញ្ចេញតេជៈ ។ ព្រះចេស្តា គឺតេជៈអំនាចនៃព្រះមហាក្សត្រ ។

តេជ (អានថា : ដែច) ន. អំនាច, អានុភាព, កំលាំង, កំដៅភ្លើង... ។ ព្រះតេជគុណ (ន) គុណនៃអំនាច រឺអំនាច និង គុណ, និមន្តព្រះតេជគុណឆាន់! ។

សេក (អានថា : សែក) ន. (សំ.បា សេក) ការស្រោចទឹក, ការប្រោះព្រំ, ការជជុះរលាស់ ។ ខ្មែរប្រើជា កិ. សំដៅសេចក្តីថា "សូត្រមន្តអាគម ប្រសិទ្ធិអោយពូកែ" ។

សេព (អានថា : សែប) កិ. (សំ.បា សេវ, វ > ព) នៅអាស្រ័យ, អាស្រ័យនៅ, រាប់រក, រាប់រកយកជាគ្នា, គប់រក, ប្រព្រឹត្ត, ប្រតិបត្តិ, ប្រើប្រាស់, បរិភោគ, ផឹក, រួមបវេណី ។ សេពសុរា ផឹកស្រា ។

ស្នេហា (អានថា : ស្នែហា) ន.រឺ គុ. (សំ. ស្នេហ, បា. សិនេហៈ រឺជាស្នេហា ដូចសំ.ដែរ) សេចក្តីស្រលាញ់

ស្និទ្ធ, សេចក្តីស្រលាញ់ជាប់ចិត្ត ស្អិតដូចជ័រ ។

សង្ខេប (អានថា : សង់ខែប) ន. (សំ.បា សំក្សេប) សេចក្តីបំព្រួញ, សេចក្តីយ៉ : និយាយដោយសង្ខេប ។ ខ្មែរប្រើជា កិ. ក៏មាន "បំព្រួញ" : រឿងសង្ខេប ។

អភិសេក (អានថា : អភិសែក) ន. (បា) ការស្រោចទឹកក្លស់ទឹកស័ង្ខ (លើព្រះសិរ្សលោកមានបុញ្ញ-ភិនិហារ) សន្មតអោយរឿងពេញទីជាក្សត្រីយ៍ទ្រង់រាជ ។ ការប្រោះព្រំបាចសាចគ្រឿងគន្ធពិដោរថ្វាយពរ ថ្វាយជ័យចំពោះព្រះពុទ្ធរូបដែលកសាងថ្មី ក៏ហៅថាអភិសេកដែរ ។ បុណ្យពុទ្ធាភិសេក ។

## II. ពាក្យខ្លះសរសេរនឹងស្រៈ " ុ " (អុ) ប្រកបនឹង "រ"

ស្រៈ " ុ " អាចប្តូរសូរជាស្រៈ " ោ "

ព្យញ្ជនៈ "រ" ប្រកបអាចប្តូរសូរជាព្យញ្ជនៈ "ល"

__ដូចជាពាក្យ:__

- កណ្តុរ អានថា កណ្តុល រឺកណ្តោ
- ខ្ទុរ អានថា ខ្ទុល រឺខ្ទោ
- ឆ្នាំកុរ អានថា ឆ្នាំកុល រឺឆ្នាំកោ
- សំបុរ អានថា សំបុល រឺសំបោ
- បង្គុរ អានថា បង្គុល រឺបង្គោ
- ..............................................

អំនាន និង សំនេរយ៉ាងនេះ ប្រហែលជាយកតាមលំនាំវេយ្យាករណ៍បាលី ព្រោះពាក្យបាលីក្នុងករណីខ្លះតំរូវអោយផ្លាស់ប្តូរស្រៈ ផ្លាស់ប្តូរព្យញ្ជនៈ តាមរបៀបវេយ្យាករណ៍បាលី ។

*__ឧទាហរណ៍:__* - ផ្លាស់ស្រៈ " ុ " ជាស្រៈ " ោ "
- ផ្លាស់ព្យញ្ជនៈ "រ" ជាព្យញ្ជនៈ "ល"
- ផ្លាស់ព្យញ្ជនៈ "វ" ជាព្យញ្ជនៈ "ព" (វិសាខបូជា ជាពិសាខបូជា, វិបាក ជា ពិបាក....)
- ផ្លាស់ព្យញ្ជនៈ "ឆ" ជាព្យញ្ជនៈ "ស" (ឆវៈ ប្រែថា : ខ្មោចស្រស់ ដូចគ្នា ...) ។

ម្យ៉ាងទៀតពាក្យខ្លះ ស្រៈ " ិ " (អិ) មានសូរជាស្រៈ " េ " (អេ)

__ដូចជាពាក្យ:__

- មិគសិរ អានថា មិគសេរ (ខែមិគសិរ) ។
- រណសិរ្ស អានថា រណសេ (រណសិរ្សសាមគ្គីសង្គ្រោះជាតិ) ។
- សិរ អានថា សេ (ក្បាល, សិរមាន់, ផ្កាសិរមាន់) ។
- ទឹកក្សិរ អានថា ទឹកក្សេរ (ទឹកដោះស្រស់) ។

លោក : **អ៊ុយ សុន**

នាយកសាលាបឋមសិក្សាព្រែកកំពឹស



# តើលោកគ្រូ អ្នកគ្រូដឹងដែរឬទេ ?

## ហេតុដូចម្ដេច ? បានជាយើង ត្រូវការ សន្តិភាព

- **ពីព្រោះ** សង្គ្រាមសំលាប់មនុស្ស មិនមែនតែកងទ័ពទេ ។ អ្នករងគ្រោះភាគច្រើនជាប្រជាជនស៊ីវិល ជាកុមារ ជាស្ត្រីមាតាផងដែរ ។
- **ពីព្រោះ** សង្គ្រាមបានបន្សល់ទុកនូវជនពិការ កុមារកំព្រា ស្ត្រីមេម៉ាយ ដែលជាបន្ទុកធ្ងន់ធ្ងរដល់សង្គមជាតិ ។
- **ពីព្រោះ** សង្គ្រាមបំផ្លាញបរិក្ខារផ្សេងៗ មានផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ផ្ទះសំបែង... ។
- **ពីព្រោះ** សង្គ្រាមបំផ្លាញសេដ្ឋកិច្ចរបស់ប្រទេសជាតិនានា ។ គេលែងអាចផលិតអ្វីបានទៀតហើយ គេខំប្រឹងត្រដររស់តែប៉ុណ្ណោះ ។
- **ពីព្រោះ** សង្គ្រាមត្រូវការចំណាយច្រើនណាស់ ។ រដ្ឋអស់លទ្ធភាពថវិកា ក្នុងការបំរើផលប្រយោជន៍ប្រជាជន ដូចជាសុខាភិបាល អប់រំ អភិវឌ្ឍន៍... ។
- **ពីព្រោះ** សង្គ្រាមបានបន្សល់ស្លាកស្នាមក្នុងខួរក្បាល និង បេះដូង ។ មនុស្សដែលបានរងនូវអំពើហិង្សា ឬបានឃើញផ្ទាល់នូវទារុណកម្ម ឬការកាប់សំលាប់ផ្សេងៗ បានត្រូវរបួស និង ដំបៅផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយបើគេពុំបានធ្វើជាកម្មវត្ថុនៃការព្យាបាលពិសេសៗទេនោះ វាអាចធ្លាក់ចូលទៅក្នុងអំពើហិង្សាយ៉ាងឆាប់រហ័ស ។

# សិល្បៈរបាំខ្មែរ

ដោយលោក : **យស់ អ៊ាង**

របាំក្បាច់បុរាណខ្មែរ "របាំព្រះរាជទ្រព្យ" ត្រូវបានអង្គការយូណេស្កូប្រកាសទទួលស្គាល់ជាសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីយនៃមនុស្សជាតិ កាលពីថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។ បន្ទាប់ពីការបញ្ចូលរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ ១៩៩២ រួចមក របាំក្បាច់បុរាណខ្មែរក៏បានក្លាយជាផ្នែកមួយនៃបេតិកភណ្ឌរបស់មនុស្សជាតិផងដែរ ។

របាំក្បាច់បុរាណខ្មែរ គឺជាកេរមរតកដែលមានអាយុកាលជាងមួយពាន់ឆ្នាំមកហើយ របាំនេះបានផ្សារភ្ជាប់ខ្លួននឹងព្រះរាជវាំងខ្មែរ ធ្លាប់បានទទួលរងនូវការលំបាកលំបិនទាំងឡាយនៃប្រវត្តិសាស្ត្រ ដែលពេលខ្លះសឹងតែរលាយបាត់បង់ ។ តែជានិច្ចកាល របាំព្រះរាជទ្រព្យត្រូវបានកកើតឡើងវិញ ម្យ៉ាងដោយទោះជានៅពេលព្រះមហាក្សត្រផ្លាស់ប្តូររាជធានីក៏ដោយក៏ក្រុមល្ខោនហ្លួងតាមដង្ហែរព្រះអង្គជាប់ជានិច្ច និង ម្យ៉ាងទៀតស្ត្រីក្មេងៗនៅតែចង់ចូលហាត់រាំ ដើម្បីបំរើក្នុងសិល្បៈដ៏ល្អត្រកាលគ្មានអ្វីប្រដូចបាននោះ ។

របាំក្បាច់បុរាណខ្មែរល្អស្រស់ប្លែកខ្លាំងណាស់ មិនអាចច្រឡំទៅនឹងរបាំដទៃទៀតបានឡើយ ។ របាំនេះមិនឈមទៅរកការរាំរួចផុតពីច្បាប់ទំនាញផែនដីដូចរបាំបាឡេនៃបច្ចឹមប្រទេស មិនបណ្តុះនូវទស្សនៈវិជ្ជាដែលមនុស្សទូទៅយល់មិនបានដូចរបាំឥណ្ឌា មិនបង្កើតស្នូរខ្ទរខ្ទារ និង ការភ័យខ្លាចដូចរបាំនៅកោះជ្វានោះឡើយ ។

ក្នុងប្រពៃណីខ្មែរ នាដ្យការីសំដែងចេញនូវឥរិយាបថទំនាក់ទំនងគ្នាជាបន្តបន្ទាប់យ៉ាងសមឥតខ្ចោះទៅតាមក្បួនរបាំពុំមានលេចចេញជារូបភាពប៉ះទង្គិច កញ្ឆក់កញ្ឆែង តែពុំមានន័យថា គ្មានការដក់ចិត្តដិតអារម្មណ៍ខ្លាំងក្នុងការទស្សនាឡើយ ។ កាយវិការទាំងឡាយត្រូវបានកំណត់ច្បាស់លាស់ទៅតាមសំលេងភ្លេង បង្កើតបាននូវការបង្ហួសកាយវិការខ្លះៗយ៉ាងទន់ភ្លន់ដែលមើលសឹងតែមិនដឹង ។ លោក George Grolier បានសរសើរកាយវិការទាំងនេះថា : "សមទំរាំនឹងមើលឃើញ នឹងស្ងើចស្ងប់ស្ងែង នឹងសោកស្តាយដែលកន្លងផុតទៅហើយ" ។

គេបានធ្វើការកត់សំគាល់សំខាន់ណាស់ទៅលើចំណុចលំអិតទាំងឡាយ ដែលគេមិនអាចមិនយកចិត្តទុកដាក់បានឡើយ ។ ពេលនេះត្រូវកាច់លើកចុងម្រាមជើង ពេលនេះត្រូវរាំកាច់បំភ្លាត់កែងដៃ ពេលនោះទៀតត្រូវរាំយកស្ថានភាពម្រាមដៃ បាតដៃអោយបានត្រឹមត្រូវទៅតាមក្បួនច្បាប់ដែលបានផ្ទេរពីជំនាន់មួយទៅជំនាន់មួយ តាំងពីយូរលង់ណាស់មកហើយ ។គ្រាន់តែក្បាច់បាតដៃ គេបានស្រង់ឃើញមានជាងមួយរយក្បាច់ ហើយគេឮថាក្បាច់បាតដៃទាំងអស់មានរហូតដល់បួនពាន់ប្រាំរយ(៤៥០០) ក្បាច់ឯណោះ ។ ក្បាច់ទាំងនេះ មិនមានតំលៃត្រឹមតែសោភ័ណប៉ុណ្ណោះទេ ។ ក្បាច់នីមួយៗប្រៀបដូចពាក្យសំដីនៃឃ្លាប្រយោគរបស់តួខ្លួនទាំងមូលងាយស្រួលយល់បែបដូចល្ខោនកាយវិការបន្តិច តែមិនមែនបែបបិទជិតឈឹងនោះឡើយ ។ នេះហើយជាតំលៃសកលនៃរបាំក្បាច់បុរាណខ្មែរ ។ លោក Rodin សិល្បករចំលាក់ដ៏ល្បីល្បាញបានពោលថា : "នាដ្យការីខ្មែរ បានផ្តល់អោយយើងនូវអ្វីទាំងអស់ដែលមាននៅសម័យបុរាណ សម័យបុរាណរបស់គេដែលគឺជារបស់យើង... ។ គេមិនអាចដែលឃើញធម្មជាតិមនុស្សឈានបានដល់សុក្រឹតភាពបែបនេះណាស់ គឺមានតែនាដ្យការីខ្មែរ និង ក្រិចប៉ុណ្ណោះ" ។

ការប្រកាសទទួលស្គាល់ស្នាដៃខ្មែរនេះ ជាការទទួលស្គាល់ជាអន្តរជាតិដ៏ថ្លៃថ្លាបំផុតនូវអ្វីដែលជាស្នាដៃដ៏អស្ចារ្យរបស់ខ្មែរយើង និង ចាត់ទុកថាសមិទ្ធផលពេលនេះ ជាមោទនភាពដ៏មហិមាសំរាប់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ។ កិត្តិយសដែលទទួលបាននាពេលនេះ គឺជាសិល្បៈតំណាងនូវចក្រភពខ្មែរបុរាណរបស់យើង ។

# ចនិកាថ្មី ស្ត្រី និង សុខភាពផ្លូវចិត្ត

## ១. តើសុខភាពផ្លូវចិត្តបណ្តាលមកពីអ្វី ?

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏ជូរចត់កន្លងមក និង ជីវភាពរស់នៅជាប្រចាំក្នុងភាពក្រីក្រ នាពេលបច្ចុប្បន្ន ដែលប្រជាពលរដ្ឋខ្មែរបានជួបការលំបាកគ្រប់បែបយ៉ាង ធ្វើអោយប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពផ្លូវចិត្ត ។ ការទទួលរងគ្រោះដោយប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ និង ជាប្រចាំកន្លងមកនេះ បណ្តាលអោយប្រជាពលរដ្ឋរងនូវជំងឺបាក់ស្បាតទាំងស្មារតី ទាំងផ្លូវកាយ និង ផ្លូវចិត្ត ។

## ២. តើជំងឺផ្លូវចិត្តមានផលវិបាកដូចម្តេចខ្លះ ?

ជំងឺផ្លូវចិត្តនៅប្រទេសកម្ពុជា ត្រូវបានរំពឹងទុកថា ជាឧបសគ្គនៃកិច្ចការអភិវឌ្ឍប្រទេសជាតិ ។

តាមការស្រាវជ្រាវនៅកម្ពុជា អត្រានៃជំងឺផ្លូវចិត្តដោយរាប់ទាំងករណីស្រាល មធ្យម និង ធ្ងន់ធ្ងរ មានកំរិតខ្ពស់ជាងប្រទេសនានាក្នុងតំបន់ ។ ចំនួនអ្នកជំងឺបានកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ។ នេះគឺបណ្តាលមកពីកង្វះខាតផ្នែកមធ្យោបាយសំរាប់ព្យាបាល និង ផលប៉ះពាល់ពីមនុស្សជំនាន់មុនដែលធ្លាប់មានជំងឺផ្លូវចិត្តរ៉ាំរ៉ៃផង និង ពីភាពក្រីក្រផង ។ ក្នុងករណីនេះ មានអ្នកជំងឺជាច្រើនដែលបានមកព្យាបាលនៅមន្ទីរពេទ្យដោយសារមានបញ្ហាទ្រុឌទ្រោម អន់ថយនូវសមត្ថភាពការងារ *(Functional impairment)* និង មានការលំបាកក្នុងការសំរបសំរួលខ្លួនរស់នៅក្នុងសង្គមជាមួយអ្នកដទៃ ។ ម្យ៉ាងទៀត ដោយអ្នកជំងឺមានអត្តចរិតមិនអាចសំរបសំរួលទៅតាមបរិយាកាស សង្គម និង គ្រួសារ ។

ឪពុកម្តាយដែលមានជំងឺធ្លាក់ទឹកចិត្ត រឺមានចរិតសង្ស័យមិនទុកចិត្តអ្នកដទៃ រឺមានការធុញថប់ ព្រួយបារម្ភមិនឈប់ឈរ ធ្វើអោយមានការប៉ះពាល់ទៅលើកូនរបស់ខ្លួន តាមរយៈឥរិយាបថ និង អាកប្បកិរិយាមិនសមស្រប និង កង្វះខាតការថ្នាក់ថ្នម ថែរក្សាបីបាច់ ផ្តល់គំរូ និង ការគាំទ្រលើកទឹកចិត្តដល់កូន ។ មូលហេតុនេះ បានធ្វើអោយក្មេងជំទង់ៗជាច្រើនដែលរស់នៅជាមួយឪពុកម្តាយ មានជំងឺធ្លាក់ទឹកចិត្តក្លាយជាអ្នកខិលខូច រហូតដល់ប្រើប្រាស់គ្រឿងញៀនទៀតផង ។ ជំងឺផ្លូវចិត្តនាំមកនូវការថយចុះនៃសមត្ថភាពពិចារណា និង សមត្ថភាពផលិត *(Reducing productivity)* ។ ជំងឺផ្លូវចិត្តនាំមកនូវភាពក្រីក្រៗនាំមកនូវរបៀបរបបរស់នៅប្រកបដោយបញ្ហាស្មុគស្មាញដែលជះឥទ្ធិពលអាក្រក់ដល់សង្គម ។ ចុងបញ្ចប់របស់ជំងឺធ្លាក់ទឹកចិត្ត បានកើតឡើងនូវ "វដ្តគ្រោះថ្នាក់"មួយ *(Vicious cycle)* ។

## ៣. តើស្ត្រីកម្ពុជាជួបប្រទះសុខភាពផ្លូវចិត្តយ៉ាងណាខ្លះ ?

ក្នុងមជ្ឈដ្ឋានស្ត្រីកម្ពុជា លក្ខណៈពិសេសនៃសុខភាពផ្លូវចិត្ត គឺផ្សារភ្ជាប់ទៅនឹងប្រពៃណីទំនៀមទំលាប់ និង វប្បធម៌ខ្មែរ ។ ក្នុងប្រពៃណីខ្មែរ ស្ត្រីជាទ្រនាប់ក្នុងចន្លោះគ្រួសារ ។ ច្បាប់ស្រី បានប្រៀនប្រដៅស្ត្រីអោយក្លាយជា

អ្នកគ្រប់គ្រងបញ្ហា "*Stress manager*" ។ ស្ត្រីត្រូវចេះរក្សាភាពស្ងៀមស្ងាត់ អំណត់ ព្យាយាម អត់ធ្មត់គ្រប់បែបយ៉ាង ដើម្បីផ្តល់សុភមង្គលក្នុងគ្រួសារ ។ មានគ្រួសារជាច្រើនដែលជួបប្រទះភាពក្រីក្រ ធ្វើអោយស្ត្រីទទួលរងនូវអំពើហិង្សាជាប្រចាំ ។ លើសពីនេះទៀត ស្ត្រីមានតួនាទីក្នុងការចិញ្ចឹមបីបាច់ និង អប់រំកូនចៅផ្ទាល់របស់ខ្លួន ។ ភារកិច្ចដ៏ច្រើននេះ ធ្វើអោយស្ត្រីជួបការលំបាក និង ជួបបញ្ហាស្មុគស្មាញជាច្រើនរហូតប៉ះពាល់ដល់សុខភាពផ្លូវចិត្ត ។ បញ្ហា សុខភាពផ្លូវចិត្តរបស់ម្តាយអាចបន្សល់ទុកដល់កូនទៀតផង ។

បច្ចុប្បន្នស្រីវ័យក្មេងជាច្រើន ត្រូវបានជួញដូរអោយបនពេស្យាចារ ហើយត្រូវបង្ខំអោយបំរើផ្លូវភេទជាមួយភ្ញៀវក្នុងមួយថ្ងៃៗជាច្រើននាក់ ។ ស្ត្រីទាំងនោះ តែងតែទទួលរងនូវការធ្វើបាបទាំងផ្លូវកាយ ទាំងផ្លូវចិត្តពីសំណាក់មេបន និង ភ្ញៀវ ហើយតែងតែបង្ខំចិត្តបញ្ចេញភាពរាក់ទាក់ទៅរកភ្ញៀវដោយក្តីអស់សង្ឃឹម និង ធ្លាក់ទឹកចិត្ត ក្នុងន័យអង្វរសុំក្តីមេត្តា ករុណាចំពោះពួកខ្លួន ។ ក្នុងចំណោមស្ត្រីដែលបំរើការងារផ្លូវភេទ គេសង្កេតឃើញមានភាពមិនសូវរវល់នឹងខ្លួនឯង ដោយគ្មានការប្រុងប្រយ័ត្នថា នឹងមានអ្វីកើតឡើងចំពោះអនាគតរបស់ខ្លួន ។

ក្នុងរឿងព្រេងខ្មែរ នាងបណ្តាចារបានក្លាយជាវិកលចរិតដោយសារតែប្តីនាងត្រូវពស់ចឹកស្លាប់ កូនទាំងពីរមួយត្រូវសត្វខ្លែងឆក់យកទៅ និង មួយទៀតត្រូវលង់ទឹកស្លាប់ ។ ប៉ុន្តែសព្វថ្ងៃស្ត្រីក្លាយជាវិកលចរិត រឺធ្លាក់ទឹកចិត្តដោយសារតែប្តីបោះបង់ចោល មិនយកចិត្តទុកដាក់ រឺប្រើអំពើហិង្សាធ្វើបាបខ្លួន ។ ចុងបញ្ចប់ វិការភាពក៏កើតមានដែលជាផលវិបាកនៃជំងឺផ្លូវចិត្ត ហើយវិការភាពនេះ ធ្វើអោយគេមិនអាចរក្សាភាពជាទ្រនាប់នៃគ្រួសារបាន ក្នុងការដោះស្រាយបញ្ហាស្មុគស្មាញ និង ជាអ្នកគ្រប់គ្រងបញ្ហាក្នុងគ្រួសារ ។

ដើម្បីដោះស្រាយបញ្ហាសុខភាពផ្លូវចិត្ត គេសង្កេតឃើញស្ត្រីវ័យចាស់ និង វ័យក្មេងជាច្រើនតែងចាកចេញពីក្រុមគ្រួសាររៀងៗខ្លួន ទៅរស់នៅទីវត្តអារាមបួសជាដូនជី ដើម្បីស្វែងរកភាពស្ងប់ស្ងាត់ បញ្ចៀសបញ្ហាស្មុគស្មាញ និង បញ្ហាសុខភាពផ្លូវចិត្ត និង បង្កើតនូវភពមួយគ្មានទុក្ខ ដោយខិតខំរៀនសូត្រធម៌ ធ្វើវិបស្សនា ប្រតិបត្តិតាមការប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

ដូចនេះ ការអប់រំគួរផ្តោតទៅលើការបង្កើនសមត្ថភាពស្ត្រីអោយមានកំរិតយល់ដឹងខ្ពស់ ដើម្បីចេះវិភាគពិចារណារកវិធីទប់ទល់នឹងបញ្ហាស្មុគស្មាញគ្រប់ប្រភេទក្នុងគ្រួសារ និង ក្នុងសង្គម ។ ការព្យាបាលសុខភាពផ្លូវចិត្តគួរតែមានកម្មវិធីពិសេសសំរាប់ស្ត្រីជំទង់ និង ស្ត្រីពេញវ័យ ។ ដោយឡែកសង្គមខ្មែរ គួរតែដូរទស្សនៈ និង ផ្តល់តំលៃចំពោះស្ត្រីដែលពីមុនប្រៀបនឹងក្រណាត់សទៅជា "រតនៈសម្បត្តិរបស់ជាតិ" ។

លោកជំទាវ : **ហួរ សុី**

**ជំងឺផ្លូវចិត្ត នាំមកនូវភាពក្រីក្រ**
**ភាពក្រីក្រ នាំមកនូវភាពស្មុគស្មាញក្នុងជីវភាពរស់នៅ**
**ដែលជាឧបសគ្គនៃកិច្ចអភិវឌ្ឍប្រទេសជាតិ ។**

សន្និសីទលើកទី ២ ស្តីពីយេនឌ័រ និង អភិវឌ្ឍន៍នៅកម្ពុជា (១៨-០៩-២០០២)

# ភាពសុខដុមក្នុងគ្រួសារ

បកប្រែពី : Comment se faire des amis

តើស្វាមី-ភរិយាម្នាក់ៗ អាចឆ្លើយតបជាវិជ្ជមាននឹងសំណួរខាងក្រោមនេះ ដែលពាក់ព័ន្ធនឹងសុជីវធម៌ ដើម្បីបង្កើតភាពសុខដុមក្នុងគ្រួសារបានឬទេ ?

**លោកប្រុសជាស្វាមី**

១- ស្វាមីគួរចេះផ្តាប់ផ្តុនភរិយាម្តងម្កាលឬទេ?ដោយជូនបាច់ផ្កា?ដោយរៀបចំខួបកំណើតរបស់ភរិយាឬខួបអាពាហ៍ពិពាហ៍?

២- ស្វាមីគួរប្រុងប្រយ័ត្នដោយមិននិយាយទិតៀនភរិយាចំពោះមុខអ្នកដទៃឬទេ ?

៣- ស្វាមីគួរផ្តល់ថវិកាមួយចំនួនចំពោះភរិយា សំរាប់ចំណាយផ្ទាល់ខ្លួនដាច់ដោយឡែកឬទេ ?

៤- ស្វាមីគួរស្វែងយល់ និង ចែករំលែកកង្វល់របស់ភរិយាដែលហត់នឿយនឹងការងារ ឬមួម៉ៅនឹងបញ្ហាអ្វីមួយឬទេ ?

៥- ស្វាមីគួរបែងចែកពេលលំហែរបស់ខ្លួនយ៉ាងតិចពាក់កណ្តាលសំរាប់ភរិយាឬទេ ?

៦- ស្វាមីគួរចេះលើកសរសើរក្នុងផលប្រយោជន៍របស់ភរិយា អំពីការប៉ិនប្រសប់របស់នាងក្នុងការធ្វើម្ហូប ក្នុងការរៀបចំផ្ទះសំបែង ក្នុងការចិញ្ចឹមថែរក្សាកូន ដោយនិយាយប្រៀបធៀបថា "ពូកែជាងម្តាយក្មេកទៀត" ឬទេ ?

៧- ស្វាមីគួរចេះបង្ហាញពីការយកចិត្តទុកដាក់របស់ខ្លួន ចំពោះជីវភាពជាបញ្ញវ័ន្ត ជានយោបាយរបស់ភរិយាឬទេ ?

៨- ស្វាមីគួរអនុញ្ញាតអោយភរិយារាំជាមួយបុរសដទៃដោយមិនបង្ហាញពីការប្រច័ណ្ឌឬទេ ?

៩- គ្រប់កាលៈទេសៈស្វាមីត្រូវចេះលើកទឹកចិត្ត និង បង្ហាញអំពីការចាប់អារម្មណ៍របស់ខ្លួនចំពោះភរិយាឬទេ ?

១០-ស្វាមីគួរចេះនិយាយអរគុណចំពោះភរិយា អំពីកិច្ចការតូចតាចដែលនាងបានជួយដូចជាការហុចនេះ ការហុចនោះជាដើមឬទេ ?

**លោកស្រីជាភរិយា**

១- ភរិយាគួរកុំចាត់ចែង ឬជ្រៀតជ្រែកកិច្ចការរបស់ស្វាមីឬទេ ? ប៉ុន្តែភរិយាអាចជូនជាការសង្កេត អំពីសហការី អំពីលេខាធិការិនី អំពីការត្រឡប់មកផ្ទះវិញយឺតម្តងម្កាលរបស់ស្វាមី ។

២- ភរិយាគួរប្រឹងប្រែងអោយអស់លទ្ធភាព ដើម្បីបង្កើតនូវភាពរីករាយក្នុងផ្ទះឬទេ ?

៣- ភរិយាគួរចេះផ្លាស់ប្តូរមុខម្ហូបដោយមិនអាចអោយស្វាមីដឹងមុន ឬទាយត្រូវថា "ថ្ងៃនេះនាងធ្វើម្ហូបអ្វី" ឬទេ ?

៤- ភរិយាគួរចេះស្វែងយល់ពីកិច្ចការរបស់ស្វាមី ក្នុងន័យជួយជាមតិយោបល់ដោយឈ្លាសវៃបំផុតឬទេ ?

៥- ភរិយាគួរបង្ហាញសេចក្តីក្លាហានក្នុងការជួយស្វាមី ចំពោះបរាជ័យក្នុងការងាររបស់គាត់ដោយមិនបន្ទោស( ពីកំហុស ឬការភ័ន្តច្រឡំ) ឬមិនប្រៀបធៀបស្វាមីជាមួយមិត្តភក្តិដែលទទួលបានជោគជ័យក្នុងមុខរបរជាងឬទេ ?

៦- ភរិយាគួរដឹងទុក្ខធុរៈក្រុមគ្រួសាររបស់ស្វាមីអោយដូចក្រុមគ្រួសាររបស់ខ្លួនឬទេ ?

៧- ភរិយាគួរចេះរៀបចំតុបតែងផ្ទះសំបែងទៅតាមចំណង់ចំណូលចិត្តរបស់ស្វាមីឬទេ ?

៨- ភរិយាគួរចេះរក្សាភាពនឹងនំ ដោយមិនបញ្ចេញយោបល់គ្មានប្រយោជន៍ ឬនិយាយអ្វីមិនបានការ ដើម្បីរក្សាភាពរីករាយក្នុងគ្រួសារឬទេ ?

៩- ភរិយាគួរចេះលេងកីឡាអ្វីដែលស្វាមីចូលចិត្ត ដើម្បីអាចចូលរួមលេងជាមួយស្វាមីក្នុងករណីចាំបាច់ឬទេ ?

១០-ភរិយាគួរស្វែងយល់ព្រឹត្តិការណ៍ជាតិ ជីវភាពសង្គមដើម្បីអាចផ្លាស់ប្តូរយោបល់ជាមួយស្វាមី អំពីទស្សនៈជាបញ្ញវ័ន្តឬទេ?

# អគារសាធារណៈ
# សាងសង់ក្នុងសម័យអាណានិគម




ប៉ុស្តិ៍ប្រៃសណីយ៍ សាងសង់ក្នុងឆ្នាំ ១៩២០ ត្រូវបានជួសជុលពង្រីក នៅឆ្នាំ ១៩៣១ និងជួសជុលលាបពណ៌សជាថ្មីនៅឆ្នាំ ១៩៩១ ។




ប៉មនាឡិកា (ហាវីសេវាកំពង់ផែ) ស្ថិតនៅខាងកើតវត្តភ្នំ ។